សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍ និងគ្រួសារ

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក. **កែវ ពេជ្រ**
លោក. **ឡុង វីរៈ**

សាស្ត្រាចារ្យណែនាំ
លោក **អម សុផាណារ៉ាត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **កែវ ពេជ្រ** និង **ឡុង ធីរៈ** ជានិស្សិតមហាវិទ្យាល័យនីតិសាស្ត្រជំនាន់ទី១៧ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងសំដែងនូវកតញ្ញូតាធមិយ៉ាងជ្រាលជ្រៅចំពោះ៖

-លោក **ឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនយ៉ាងយកចិត្តទុកដាក់។ ជាពិសេស លោកទាំងពីរតែងតែផ្គត់ផ្គង់ទំនុកបម្រុងកូនទាំងផ្នែកសម្ភារៈ ថវិកា ស្មារតី ព្រមទាំងផ្តល់ដំបូន្មានល្អៗដែលជួយជម្រុញទឹកចិត្តកូនក្នុងការរៀនសូត្រផងដែរ។

-កុង **ម៉ូ គុយសេង** និងអ្នកមីង **ពឹង ស៊ូហុង** ដែលបានទូន្មានប្រៀនប្រដៅ និងផ្គត់ផ្គង់ទំនុកបម្រុងទាំងផ្នែកសម្ភារៈ និងថវិកា សម្រាប់ការរៀនសូត្រ។

-រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលលោកបានដាក់ចេញនូវគោលនយោបាយល្អៗ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

-ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចណ្ណា** សាកលវិទ្យាធិការរង លោកគ្រូ និងអ្នកគ្រូ ដែលលោកបានបង្ហាត់បង្រៀនយើងខ្ញុំ ដោយពុំគិតចង់បានអ្វីជាការតបស្នងក្រៅពីការខិតខំបំពេញភារកិច្ចរបស់គាត់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងមន្ត្រី និងបុគ្គលិកទាំងអស់ដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

-ជាពិសេស លោកគ្រូ **អម សុផាណារ៉ាត** ជាសាស្ត្រាចារ្យទទួលបន្ទុកដឹកនាំក្នុងការសរសេរសារណាដែលលោកបានខិតខំទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការផ្តល់យោបល់ ចំណេះដឹង និងបទពិសោធន៍នានាដែលលោកមានមកឲ្យយើងខ្ញុំទាំងពីរនាក់ ដោយនេះជាកត្តាដ៏សំខាន់ដែលយើងខ្ញុំទាំងពីរនាក់អាចឈានទៅដល់ការសរសេរសារណាប្រកបដោយភាពជោគជ័យ។

ជាចុងបញ្ចប់ យើងខ្ញុំសូមគោរពនូវការដឹងគុណ និងសូមជូនពរដល់លោកឪពុក-អ្នកម្តាយ លោកគ្រូ និងអ្នកគ្រូទាំងអស់ឲ្យប្រកបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងសង្គមកម្ពុជា ចំណងអាពាហ៍ពិពាហ៍គឺជាដំណាក់កាលដ៏សំខាន់ក្នុងការឈានទៅដល់ការបង្កើតគ្រួសារមួយដោយស្របច្បាប់។ ប៉ុន្តែទោះបីជាមានទំនៀមទម្លាប់ប្រពៃណីរួមទាំង ច្បាប់មួយចំនួនផងដែរដូចជា ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏ដោយ ប្រជាពលរដ្ឋខ្មែរមួយចំនួននៅបន្តអនុវត្តតាមបែប ប្រពៃណី និងសាសនា ដែលការអនុវត្តទាំងនេះមានលក្ខណៈផ្ទុយនឹងច្បាប់ និងមិនមានអានុភាពចំពោះការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ។

ដោយមានឆន្ទៈចង់ចងក្រងឯកសារមួយចំនួនដែលទាក់ទងទៅនឹងអាពាហ៍ពិពាហ៍ និងគ្រួសារ ដើម្បីចែក រំលែកនូវភាពស្របច្បាប់នៃអាពាហ៍ពិពាហ៍នៅក្នុងសង្គមកម្ពុជា យើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្ត ចងក្រងនូវឯកសារសារណាមួយដែលមានឈ្មោះថា "**អាពាហ៍ពិពាហ៍ និងគ្រួសារ**"។ យើងខ្ញុំទាំងពីរ នាក់មានជំនឿយ៉ាងមុតមាំថា សារណាមួយនេះនឹងអាចជួយដល់គូស្រករដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នាអាចយល់ដឹងពីលក្ខខណ្ឌស្របច្បាប់មួយចំនួន ដើម្បីឲ្យពិធីរៀបអាពាហ៍ពិពាហ៍ ព្រមទាំងចំណងអាពាហ៍ពិពាហ៍របស់ពួកគេស្ថិតនៅបានគង់វង្ស។ លើសពីនេះទៅទៀត សារណាមួយនេះនឹង អាចជួយពន្យល់បន្ថែមដល់និស្សិតជំនាន់ក្រោយឲ្យយល់ដឹងកាន់តែច្បាស់នូវអាពាហ៍ពិពាហ៍ និងគ្រួសារ នៅក្នុងសង្គមកម្ពុជា។

មួយវិញទៀតផងដែរ ទោះបីប្រទេសយើងមានច្បាប់ និងទំនៀមទម្លាប់ប្រពៃណីល្អយ៉ាងណាក៏ដោយ ប្រសិនបើគ្មានការចូលរួមពីសំណាក់បងប្អូនប្រជាពលរដ្ឋទាំងអស់គ្នាទេ នោះច្បាប់ និងទំនៀមទម្លាប់ប្រពៃណីនេះនឹងមិនមានអានុភាពឡើយ ហើយវានឹងបាត់បង់ទៅវិញនៅថ្ងៃណាមួយជាមិនខាន។ ដូចនេះ យើងខ្ញុំទាំងពីរនាក់សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាចូលរួមទាំងអស់គ្នាក្នុងការអនុវត្ត និងគោរពតាមបទដ្ឋានជាធរមាន ព្រមទាំងប្រពៃណីដ៏មានតម្លៃដែលដូនតាយើងបានបន្សល់ទុកឲ្យបានគង់វង្ស និងស្ថិតស្ថេរជារៀងរហូត។

ម្យ៉ាងវិញទៀត ទន្ទឹមនឹងមានចំណុចវិជ្ជមាន ចំណុចអវិជ្ជមានមួយចំនួនក៏តែងតែកើតឡើងផងដែរ។ ដូចនេះហើយ យើងខ្ញុំសូមឲ្យបងប្អូនមិត្តនិស្សិត ក៏ដូចជាមិត្តអ្នកអានទាំងអស់មេត្តាជួយកែតម្រូវ និងបំពេញបន្ថែមនូវចំណុចខ្វះខាត និងកំហុសឆ្គងដោយអចេតនារបស់យើងខ្ញុំដោយក្តីអនុគ្រោះ។

# មាតិកា

**ទំព័រ**


**សេចក្ដីផ្ដើម** ..................................................... ០១

**ជំពូកទី១**

**អាពាហ៍ពិពាហ៍ និងគ្រួសារ**

**ផ្នែកទី១៖ សញ្ញាណនៃអាពាហ៍ពិពាហ៍ និងគ្រួសារ** ..................... ០២

**កថាខណ្ឌ១៖ សញ្ញាណអាពាហ៍ពិពាហ៍** ..................... ០២

**កថាខណ្ឌ២៖ សញ្ញាណគ្រួសារ** ..................... ០២

**កថាខណ្ឌ៣៖ និយមន័យអាពាហ៍ពិពាហ៍ និងគ្រួសារ** ..................... ០២

**ផ្នែកទី២៖ លក្ខខណ្ឌមុនពេលរៀបអាពាហ៍ពិពាហ៍** ..................... ០២

**កថាខណ្ឌ១៖ ការចែចូវ** ..................... ០២

**កថាខណ្ឌ២៖ ការស្ដីដណ្ដឹង** ..................... ០៣

**កថាខណ្ឌ៣៖ កំជាប់ពាក្យ** ..................... ០៣

**១. ការសងជំនូន** ..................... ០៣

**២. ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ** ..................... ០៣

**៣. ការដាក់ពាក្យបណ្ដឹង** ..................... ០៤

**ផ្នែកទី៣៖ លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍** ..................... ០៤

**កថាខណ្ឌ១៖ លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍** ..................... ០៤

**១. ភេទខុសគ្នា** ..................... ០៤

**២. អាយុ** ..................... ០៤

**៣. ការព្រមព្រៀងរបស់គូស្រករ** ..................... ០៤

**៤. ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន** ..................... ០៤

**៤.១. ជនទទួលបានអត្តាធីនភាព** ..................... ០៤

**៤.២. អនីតិជន និងនីតិជន** ..................... ០៥

**៥. ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ** ..................... ០៥

**៦. ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាព** ..................... ០៥

៧. អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត.............................. ០៦
៨. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ខាងញាតិលោហិត........................ ០៦
៩. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ខាងញាតិពន្ធ .............................. ០៦
កថាខណ្ឌ២៖ លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍..............................................០៧
១. លក្ខខណ្ឌមុនរៀបអាពាហ៍ពិពាហ៍..................................................................០៧
១.១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍.......................................................០៧
១.២. ការប្រកាសផ្សាយ.......................................................................................០៧
១.២.១. គោលបំណង ........................................................................................០៧
១.២.២. បែបបទប្រកាសផ្សាយ ..........................................................................០៧
១.២.៣. រយៈពេលប្រកាសផ្សាយ........................................................................ ០៨
២. លក្ខខណ្ឌក្នុងពេលរៀបអាពាហ៍ពិពាហ៍ ......................................................... ០៨
២.១. វត្តមានគូស្រករ ........................................................................................ ០៨
២.២. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍................................................................ ០៨
២.៣. សមត្ថកិច្ចមន្ត្រីអត្រានុកូលដ្ឋាន ............................................................... ០៨

## ជំពូកទី២

## អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស

ផ្នែកទី១៖ អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស ......... ០៩
កថាខណ្ឌ១៖ ការរៀបអាពាហ៍ពិពាហ៍នៅបរទេស ............................................. ០៩
កថាខណ្ឌ២៖ ការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា............................. ០៩
១. ពលរដ្ឋខ្មែរ-ជនបរទេស ឬ ជនអន្តោប្រវេសន៍ ............................................ ០៩
១.១. លក្ខខណ្ឌ ............................................................................................. ០៩
១.២. ឯកសារ................................................................................................ ១០
១.៣. ការពិនិត្យ និងការប្រកាសផ្សាយរបស់មន្ត្រីអត្រានុកូលដ្ឋាន ................ ១១
១.៤. ការចុះសំបុត្រអាពាហ៍ពិពាហ៍ ................................................................ ១១
២. ជនបរទេស-ជនបរទេស ................................................................................ ១២
កថាខណ្ឌ៣៖ ការរំលាយអាពាហ៍ពិពាហ៍.......................................................... ១២

១. នៅបរទេស ........................................................................................................ ១២
២. នៅប្រទេសកម្ពុជា ............................................................................................ ១២
ផ្នែកទី២៖ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍......................................... ១២
កថាខណ្ឌ១៖ មោឃភាពនៃអាពាហ៍ពិពាហ៍...................................................... ១២
១. មោឃភាពដាច់ខាត ............................................................................................ ១២
១.១. ការតាន់ច្រឡំលើមនុស្ស................................................................................... ១២
១.២. ការបង្ខិតបង្ខំ .....................................................................................................១៣
២. មោឃភាពមិនដាច់ខាត...........................................................................................១៣
២.១. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍...........................................................១៣
២.២. ភាគីមិនបានជូនដំណឹងជាសាធារណៈ.................................................................១៣
២.៣. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍..............................................................១៣
២.៤. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ......................................................................១៣
កថាខណ្ឌ២៖ ការលុបចោលអាពាហ៍ពិពាហ៍ ...................................................... ១៤
១. អាពាហ៍ពិពាហ៍មិនគ្រប់អាយុ ........................................................................... ១៤
២. ទ្វេពន្ធភាព ..................................................................................................... ១៤
៣. អំឡុងពេលរៀបអាពាហ៍ពិពាហ៍ថ្មី......................................................................... ១៤
៤. ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត ........................................................ ១៥
៥. ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ.................................................................. ១៥
៦. ការឆបោក............................................................................................................ ១៥
៧. ការគំរាមកំហែង................................................................................................... ១៥
ផ្នែកទី៣៖ អានុភាពនៃអាពាហ៍ពិពាហ៍..................................................................... ១៦
កថាខណ្ឌ១៖ សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ............................................... ១៦
១. ករណីយកិច្ចគោរពគ្នារវាងញាតិ និងការបង្ការអំពើហិង្សាក្នុងគ្រួសារ........... ១៦
២. នាមត្រកូលរបស់ប្តីប្រពន្ធ ................................................................................ ១៦
៣. ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក .............. ១៦
៤. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម ..... ១៦
៥. ករណីយកិច្ចចិញ្ចឹមបីបាច់ ថែរក្សា និងអប់រំកូន ..............................................១៧
កថាខណ្ឌ២៖ ទំនាក់ទំនងឪពុកម្តាយ និងកូន ....................................................១៧

១. ទំនាក់ទំនងឪពុកម្ដាយបង្កើត និងកូនបង្កើត .......... ១៧

១.១. ករណីយកិច្ចនៃការចុះសំបុត្រកំណើត .......... ១៧

១.២. ការសម្រេចអំពីបុត្តភាព .......... ១៧

១.២.១. មាតុភាព .......... ១៧

១.២.២. បិតុភាព .......... ១៨

១.២.២.១. លក្ខខណ្ឌនៃបិតុភាព .......... ១៨

១.២.២.២. ការបដិសេធបិតុភាព .......... ១៨

១.៣. ការទទួលស្គាល់បិតុភាព .......... ១៩

១.៣.១. ការទទួលស្គាល់ដោយស្ម័គ្រចិត្ត .......... ១៩

១.៣.២. សមត្ថភាពក្នុងការទទួលស្គាល់ .......... ១៩

១.៣.៣. ការទទួលស្គាល់របស់ឪពុក .......... ១៩

១.៣.៣.១. កូនជាអនីតិជន .......... ១៩

១.៣.៣.២. កូនជានីតិជន និងកូនដែលបានទទួលមរណភាព .......... ១៩

១.៣.៣. ទម្រង់នៃការទទួលស្គាល់ .......... ១៩

១.៣.៤. អានុភាពនៃការចុះកំណើត និងការទទួលស្គាល់ .......... ១៩

១.៣.៥. បណ្ដឹងទាមទារឲ្យទទួលស្គាល់ .......... ២០

២. ការសុំកូន .......... ២០

២.១. សុំកូនធម្មតា .......... ២១

២.១.១. លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា .......... ២១

២.១.១.១. លក្ខខណ្ឌគ្រឹះ .......... ២១

២.១.១.២. លក្ខខណ្ឌទម្រង់ .......... ២២

២.១.២. អានុភាពនៃសុំកូនធម្មតា .......... ២២

២.១.៣. ការកាត់កាល់សុំកូនធម្មតា .......... ២២

២.១.៣.១. លក្ខខណ្ឌនៃការកាត់កាល់តាមការព្រមព្រៀង .......... ២២

២.១.៣.២. លក្ខខណ្ឌនៃការកាត់កាល់តាមផ្លូវតុលាការ .......... ២២

២.១.៤. អានុភាពនៃការកាត់កាល់ .......... ២៣

២.២. សុំកូនពេញលេញ .......... ២៣

២.២.១. លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ .......... ២៣

២.២.១.១. លក្ខខណ្ឌគ្រឹះ ........................................................... ២៣

២.២.១.២. លក្ខខណ្ឌទម្រង់ ........................................................... ២៤

២.២.២. អានុភាពនៃស្ទុំពេញលេញ ........................................................... ២៤

២.២.៣. ការកាត់កាល់ស្ទុំកូនពេញលេញ ........................................................... ២៥

២.២.៣.១. អានុភាពនៃការកាត់កាល់ ........................................................... ២៥

កថាខណ្ឌ៣៖ ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ........................................................... ២៥

១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ........................................................... ២៥

២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ........................................................... ២៦

២.១. ទ្រព្យសម្បត្តិដោយឡែក ........................................................... ២៦

២.២. ទ្រព្យសម្បត្តិរួម ........................................................... ២៦

៣. ការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ........................................................... ២៧

៣.១. ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ........................................................... ២៧

៣.២. ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះភាគព្វកិច្ច ........................................................... ២៧

៣.៣. ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ........................................................... ២៨

៤. ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក ........................................................... ២៨


## ជំពូកទី៣

## អំពីការលែងលះ


ផ្នែកទី១៖ សញ្ញាណនៃការលែងលះ ........................................................... ២៩

កថាខណ្ឌ១៖ មូលហេតុនៃការលែងលះ ........................................................... ២៩

១. បានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ ........................................................... ២៩

២. បានបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ........................................................... ២៩

៣. មិនបានដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ... ៣០

៤. សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ... ៣០

៥. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបាក់បែក .......... ៣១

កថាខណ្ឌ២៖ មូលហេតុរារាំងនៃការលែងលះ ........................................................... ៣២

កថាខណ្ឌ៣៖ លក្ខខណ្ឌនៃការលែងលះ ........................................................... ៣២

១. ការលែងលះដោយឯកតោភាគី ... ៣២
១.១. ការលែងលះដោយកំហុស ... ៣២
១.២. ការលែងលះដោយឥតកំហុស ... ៣២
២. ការលែងលះដោយការព្រមព្រៀង ... ៣៣
កថាខណ្ឌ៤៖ នីតិវិធីនៃការលែងលះ ... ៣៣
១. អ្នកដាក់ពាក្យបណ្ដឹង ... ៣៣
២. កន្លែងដាក់ពាក្យបណ្ដឹង ... ៣៤
៣. ស្ថាប័នមានសមត្ថកិច្ច ... ៣៤
៣.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ... ៣៤
៣.២. តុលាការ ... ៣៥
៣.២.១. ការពិនិត្យពាក្យបណ្ដឹង ... ៣៥
៣.២.២. ការបញ្ជូនពាក្យបណ្ដឹង ... ៣៥
៣.២.៣. ការកំណត់កាលបរិច្ឆេទសម្រាប់ការទាញហេតុផលលើកដំបូង ... ៣៥
៣.២.៤. ឯកសារត្រៀម ... ៣៦
៣.២.៥. នីតិវិធីសម្រាប់ការទាញហេតុផល ... ៣៦
៣.២.៦. ការទាញហេតុផលដោយផ្ទាល់មាត់ ... ៣៧
៣.២.៧. ការចេញសាលក្រម ... ៣៨
៣.២.៧.១. អត្ថន័យនៃសាលក្រម ... ៣៨
៣.២.៧.២. ការចូលជាស្ថាពររបស់សាលក្រម ... ៣៩
៣.២.៧.៣. អានុភាពនៃសាលក្រមស្ថាពរ ... ៣៩
៤. ការចាត់ចែងរក្សាការពារ ... ៣៩
ផ្នែកទី២៖ អានុភាពនៃការលែងលះ ... ៤០
កថាខណ្ឌ១៖ ការរំលាយចំណងអាពាហ៍ពិពាហ៍ ... ៤០
កថាខណ្ឌ២៖ ការបែងចែកទ្រព្យសម្បត្តិ ... ៤០
១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ... ៤១
២. ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់ ... ៤១
២.១. ទ្រព្យសម្បត្តិដោយឡែក ... ៤១
២.២. ទ្រព្យសម្បត្តិរួម ... ៤១

កថាខណ្ឌ៣៖ ការប្រគល់អំណាចមេបា ..... ៤២
១. តាមការព្រមព្រៀង ..... ៤២
២. មិនតាមការព្រមព្រៀង ..... ៤២
កថាខណ្ឌ៤៖ ការព្យួរ និងការដកហូតអំណាចមេបា ..... ៤៣
១. មូលហេតុនៃការព្យួរ និងការដកហូតអំណាចមេបា ..... ៤៤
២. ការផ្លាស់ប្តូរអ្នកមានអំណាចមេបា ..... ៤៤
កថាខណ្ឌ៤៖ អាហារកិច្ច ..... ៤៤
១. អាហារកិច្ចចំពោះកូន ..... ៤៤
២. ការមិនផ្តល់អាហារកិច្ច ..... ៤៤
**សេចក្តីសន្និដ្ឋាន ..... ៤៥**
**អនុសាសន៍ ..... ៤៦**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

វប្បធម៌ អរិយធម៌ និងទំនៀមទម្លាប់ប្រពៃណីនៃព្រះរាជាណាចក្រកម្ពុជា គឺពិតជាមានតម្លៃឥតគណនាបាន។ ការរៀបអាពាហ៍ពិពាហ៍ដើម្បីបង្កើតគ្រួសារមួយស្របច្បាប់ដែលសង្គមទទួលស្គាល់ គឺមាន៤ដំណាក់កាលដូចជា ការចែចូវ ការស្តីដណ្តឹង ភ្ជាប់ពាក្យ និងពិធីរៀបអាពាហ៍ពិពាហ៍។ ដំណាក់កាលទាំង៤នេះបានបង្ហាញពិភពលោកឲ្យស្គាល់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អ ដែលដូនតាយើងបានបន្សល់ទុកឲ្យ។ លើសពីនេះទៅទៀត ក្នុងគោលបំណងអភិរក្ស និងថែរក្សានូវទំនៀមទម្លាប់ដ៏ល្អផូរផង់នេះ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តក្រមរដ្ឋប្បវេណីនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

ការរៀបអាពាហ៍ពិពាហ៍ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងសង្គមកម្ពុជា។ ដោយគូស្រករទាំងពីរនាក់មានបំណងរួមរស់ជាមួយគ្នាជារៀងរហូត ពួកគេទាំងពីរត្រូវតែឆ្លងកាត់ការរៀបអាពាហ៍ពិពាហ៍ជាមុនសិន និងឈានទៅដល់ការចុះសំបុត្រអាពាហ៍ពិពាហ៍ ទើបពួកគេក្លាយជាគូស្វាមីភរិយាស្របច្បាប់។ មិនតែប៉ុណ្ណោះ កូន សិទ្ធិ និងករណីយកិច្ច ព្រមទាំងទ្រព្យសម្បត្តិរបស់ ពួកគេត្រូវបានកំណត់យ៉ាងច្បាស់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ប្រសិនបើពួកគេមិនមានបំណងបន្តចំណងអាពាហ៍ពិពាហ៍ ហើយឈានទៅដល់ការលែងលះ។

ទោះបីជាមានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ក៏ដោយ អាពាហ៍ពិពាហ៍ផ្ទុយច្បាប់នៅតែជាជម្ងឺរ៉ាំរ៉ៃ និងបន្តរាតត្បាតសង្គមកម្ពុជា។ អនីតិសង្វាសដែលជាមូលហេតុចម្បងនៃការស្វែងរកបិតុភាព និងមាតុភាព ក៏នៅបន្តកើតឡើងផងដែរ។ នេះហើយជាមូលហេតុមួយចំនួនដែលត្រូវបានបង្កើតឡើងដោយអាពាហ៍ពិពាហ៍ផ្ទុយច្បាប់។

ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយស្របច្បាប់ តើគេត្រូវគោរពលក្ខខណ្ឌគតិយុត្តអ្វីខ្លះ? តើអាពាហ៍-ពិពាហ៍នៅបរទេស និងអាពាហ៍ជាមួយជនបរទេស តើគេត្រូវធ្វើដូចម្តេចខ្លះ? តើមានមូលហេតុអ្វីខ្លះដែលបណ្តាលឲ្យមានការលែងលះ?

ដូចនេះ ដើម្បីឲ្យកាន់តែជ្រាបច្បាស់នៃការរៀបអាពាហ៍ពិពាហ៍មួយស្របច្បាប់ អាពាហ៍-ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស និងមូលហេតុនៃការលែងលះ យើងខ្ញុំជានិស្សិតស្រាវជ្រាវនូវប្រធានបទខាងលើ សូមលើកយកចំណុច៣មកបកស្រាយគឺ៖

**ជំពូកទី១៖ អាពាហ៍ពិពាហ៍ និងគ្រួសារ**

**ជំពូកទី២៖ អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស**

**ជំពូកទី៣៖ ការលែងលះ**

# ជំពូកទី១
# អាពាហ៍ពិពាហ៍ និងគ្រួសារ

## ផ្នែកទី១៖ សញ្ញាណនៃអាពាហ៍ពិពាហ៍ និងគ្រួសារ

### កថាខណ្ឌ១៖ សញ្ញាណអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាមូលដ្ឋានរបស់គ្រួសារ ព្រោះបុរស និងស្ត្រីជ្រើសរើសយកគ្នាជាគូស្វាមីភរិយា មានគោលបំណងកសាងគ្រួសារមួយ។ ចំណែកឯគ្រួសារវិញ គឺជាកោសិការបស់សង្គម អនុវត្តភារៈសំខាន់របស់សង្គម គឺភារៈពីការបង្កើត ភារៈពីការអប់រំ និងភារៈពីការកសាងសេដ្ឋកិច្ច។

ម្យ៉ាងទៀត អាពាហ៍ពិពាហ៍ គឺជាចំណងមនោសញ្ចេតនារវាងបុរសម្នាក់ជាមួយស្ត្រីម្នាក់ដោយឈរលើមូលដ្ឋាន និងសមភាព ហើយត្រូវបានច្បាប់ទទួលស្គាល់។

ដូចនេះ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ[1]។

### កថាខណ្ឌ២៖ សញ្ញាណគ្រួសារ

ពាក្យ "គ្រួសារ" មានន័យទូលាយជាងពាក្យ "អាពាហ៍ពិពាហ៍" ព្រោះគ្រួសារមានមនុស្សច្រើន ហើយគ្រួសារកើតឡើងអាស្រ័យដោយមូលដ្ឋាននៃចំណងអាពាហ៍ពិពាហ៍ ញាតិលោហិត និងការចិញ្ចឹមបីបាច់ថែរក្សាគ្នា ហើយសិទ្ធិ និងកាតព្វកិច្ចរបស់គ្រួសារត្រូវបានកំណត់ដោយច្បាប់។

### កថាខណ្ឌ៣៖ និយមន័យអាពាហ៍ពិពាហ៍ និងគ្រួសារ

អាពាហ៍ពិពាហ៍ និងគ្រួសារ គឺជាចំណងអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី មានន័យថា បុរស ឬ ស្ត្រី ដែលមានវ័យគ្រប់ការតាមច្បាប់កំណត់អាចជ្រើសរើសយកប្តី ឬ ប្រពន្ធបានដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំពីអ្នកដទៃឡើយ គឺមានសេរីភាពគ្រប់គ្រាន់ក្នុងការជ្រើសរើស។ គេក៏មានសេរីភាពក្នុងការលែងលះដែរ បើយល់ឃើញថា គេពុំអាចរស់នៅ និងកសាងសុភមង្គលគ្រួសារបាន។

## ផ្នែកទី២៖ លក្ខខណ្ឌមុនពេលរៀបអាពាហ៍ពិពាហ៍

### កថាខណ្ឌ១៖ ការចែចូវ

ទោះបីជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានចែងអំពីការចែចូវ ប៉ុន្តែការចែចូវ គឺជាទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ ដែលវាជាដំណាក់កាលដំបូងមុននឹងឈានដល់ពិធីរៀបអាពាហ៍ពិពាហ៍។ ការចែចូវ គឺជាការចូលសាកសួររបស់ភាគីបុរសទៅលើភាគីនារីដើម្បីចង់ដឹងថា តើភាគីនារីមានគូកំណាន់ចិត្តហើយ ឬ នៅ?

[1] សាស្ត្រាចារ្យ អម សុផាណារ៉ាត, ២០១៤-២០១៥. នីតិរដ្ឋប្បវេណី

**កថាខណ្ឌ២៖ ការស្ដីដណ្ដឹង**

បន្ទាប់ពីបុរសបានចូលស្ទូនាំអំពីសារតា និងទំនាក់ទំនងផ្សេងៗដែលទាក់ទងនឹងភាគីនារីរួច ហើយ កាលបើដឹងច្បាស់ហើយថា ភាគីនារីនៅទំនេរ ហើយភាគីបុរសនៅតែមានបំណងចង់បានភាគីនារីមកធ្វើជាភរិយា ឪពុកម្ដាយខាងបុរសនឹងរកចៅមហាដើម្បីចូលស្ដីដណ្ដឹង។

**កថាខណ្ឌ៣៖ កំជាប់ពាក្យ**

ពិធីភ្ជាប់ពាក្យ ជាប្រពៃណីខ្មែរដែលមានតាំងពីបរមបុរាណមក ហើយក៏ជាពិធីដ៏ធំមួយមុននឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍។ នៅពេលសព្វថ្ងៃ ពិធីនេះនៅមានការនិយមធ្វើជាទូទៅ មុននឹងកូនប្រុសស្រីរបស់គេឈានទៅដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ហើយក្នុងគ្រួសារដែលមានជីវភាពធូរធារ បានរៀបចំពិធីនេះយ៉ាងអធិកអធមធំប៉ុនគ្នានឹងពិធីរៀបអាពាហ៍ពិពាហ៍ដែរ។ ពីធីនេះ គេច្រើនធ្វើមួយព្រឹក ឬ មួយថ្ងៃពេញតែម្ដង ហើយមានការបំពាក់ចិញ្ចៀន ឬ ខ្សែក ឬ ក៏ការប្រគល់វត្ថុអនុស្សាវរីយ៍ដល់អនាគតស្វាមី ឬ ភរិយាទៀតផង តាមការនិយម និងតាមសមត្ថភាពធនធានដែលភាគីមាន[2]។

កំជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្ដីសន្យារវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នានាពេលអនាគត និងដោយធ្វើពិធីកំជាប់ពាក្យ[3]។

**១. ការសងជំនូន**

ក្នុងករណីដែលកំជាប់ពាក្យបានរលាយ ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យ ដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឲ្យភាគីម្ខាងទៀតសងជំនូននោះមកវិញបាន[4]។ ជាទូទៅ ការសងជំនូន គឺធ្វើឡើងនៅពេលដែលភាគីទាំងពីរបានព្រមព្រៀងគ្នារំលាយពិធីរៀបអាពាហ៍ពិពាហ៍ ហើយភាគីនារីត្រូវសងជំនូនទៅភាគីបុរសវិញ។ មូលហេតុនៃការសងជំនូនមានដូចជា ភាគីទាំងពីរបានព្រមព្រៀងគ្នារំលាយពិធីអាពាហ៍ពិពាហ៍ ការមានវិការៈផ្សេងៗមុនពេលពិធីរៀបអាពាហ៍ពិពាហ៍ (ភាគីម្ខាងមិនពេញចិត្ត ឬ អស់មនោសញ្ចេតនានឹងភាគីម្ខាងទៀត) មរណៈភាពរបស់ភាគីម្ខាងជាដើម។

**២. ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ**

ក្នុងករណីដែលភាគីណាម្ខាងបានបដិសេធកំជាប់ពាក្យដែលបានភ្ជាប់រវាងភាគីចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការបដិសេធចោលនោះបាន[5]។ សំណងនៃការខូចខាតនេះ គឺចង់សំដៅទៅលើសំណងផ្លូវចិត្ត ការចំណាយប្រាក់ក្នុងការត្រៀមរៀបចំពិធីជាដើម។

[2] សាស្ត្រាចារ្យ ឥន យឿន, ២០១៣. នីតិគ្រួសារ និងអាពាហ៍ពិពាហ៍

[3] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៤៤

[4] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៤៥

[5] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៤៦

**៣. ការដាក់ពាក្យបណ្តឹង**

ការប្តឹងទាក់ទងទៅនឹងការសងជំនួន និងការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ ត្រូវប្តឹងក្នុងអំឡុងពេល១ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះបានរលាយ[6]។

**ផ្នែកទី៣៖ លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍**

**កថាខណ្ឌ១៖ លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍**

**១. ភេទខុសគ្នា**

ដើម្បីរៀបអាពាហ៍ពិពាហ៍ គូស្រករទាំងពីរត្រូវតែមានភេទផ្ទុយគ្នា[7]។ ចំពោះអាពាហ៍ពិពាហ៍ដែលមានភេទដូចគ្នា អាពាហ៍ពិពាហ៍នោះនឹងមិនត្រូវបានទទួលស្គាល់ដោយច្បាប់នោះទេ។

**២. អាយុ**

បុរស និងនារី ដែលមិនទាន់ដល់នីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលទូទៅសម្រាប់អនីតិជនរបស់អនីតិជននោះ[8]។

ដូចនេះ ជនប្រុសស្រីទាំងអស់ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចរៀបអាពាហ៍ពិពាហ៍បានដោយការសម្រេចចិត្តរបស់ខ្លួន ដោយមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬ អាណាព្យាបាល។

**៣. ការព្រមព្រៀងរបស់គូស្រករ**

បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ អាពាហ៍ពិពាហ៍ត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយ ប្រពន្ធមួយ[9]។ ដូចនេះ គោលការណ៍ចម្បងនៃការរៀបអាពាហ៍ពិពាហ៍ គឺការស្ម័គ្រចិត្តរបស់គូស្រករទាំងពីរ ដែលមានបំណងរួមរស់ជាមួយគ្នា។ ប្រសិនបើគ្មានការព្រមព្រៀងរបស់គូស្រករទាំងពីរនោះទេ ការរៀបអាពាហ៍ពិពាហ៍មិនអាចធ្វើទៅបានឡើយ។

**៤. ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន**

**៤.១. ជនទទួលបានអត្តាធីនភាព**

អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកជានីតិជន[10]។ ដូចនេះ អនីតិជនដែលទទួលបានអត្តាធីនភាពនេះមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ ដោយមិនចាំបាច់មានការយល់ព្រមពីឪពុក

---

[6] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៤៧

[7] សាស្ត្រាចារ្យ អម សុផាណារ៉ាត, ២០១៤-២០១៥. នីតិរដ្ឋប្បវេណី

[8] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៤៨

[9] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា៤៥

[10] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា២២

ម្ដាយ ឬ អាណាព្យាបាល។ ក្នុងករណីដែលអាពាហ៍ពិពាហ៍នោះកើតឡើងរវាងអនីតិជនទទួលបានអត្តាធីនភាព និងអនីតិជន ការរៀបអាពាហ៍ពិពាហ៍នោះត្រូវមានការយល់ព្រមពីឪពុកម្ដាយ។ ប៉ុន្តែប្រសិនបើអាពាហ៍ពិពាហ៍នោះកើតឡើងរវាងអនីតិជនដែលទទួលបានអត្តាធីនភាពទាំងសងខាង ឬទាំងពីរ ពួកគេអាចរៀបអាពាហ៍ពិពាហ៍បានទោះបីជាមានការប្រឆាំងពីឪពុកម្ដាយក៏ដោយ។

**៤.២. អនីតិជន និងនីតិជន**

ក្នុងករណីដែលអាពាហ៍ពិពាហ៍ធ្វើឡើងរវាងអនីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំ ជាមួយនីតិជន ការរៀបអាពាហ៍ពិពាហ៍នេះត្រូវមានការយល់ព្រមពីឪពុកម្ដាយ ឬ អាណាព្យាបាលទូទៅសម្រាប់អនីតិជនរបស់អនីតិជននោះ[11]។ ក្នុងករណីនេះផងដែរ ប្រសិនបើអ្នកមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាងទៀត វាជាការគ្រប់គ្រាន់[12]។ ប៉ុន្តែករណីនេះអាចធ្វើទៅបានលុះត្រាតែគូស្រករទាំងពីរពិតជាមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាពិតមែន។

**៥. ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ**

ជននៅក្រោមអាណាព្យាបាលទូទៅ (ជនវិកលចរិត) ហើយជានីតិជន អាចរៀបអាពាហ៍ពិពាហ៍បានក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរិមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ[13]។ មានន័យថា ជនវិកលចរិតនេះអាចសម្រេចចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯងបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ។

**៦. ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាព**

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ[14]។ ដូចនេះបុរស ឬ ស្ត្រី ដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយ ហើយអាពាហ៍ពិពាហ៍នោះនៅមានសុពលភាព ពួកគេមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានទៀតឡើយ។ ប៉ុន្តែក្នុងករណីដែលបុរស ឬ ស្ត្រីនោះបានលួចទៅរៀបអាពាហ៍ពិពាហ៍ថ្មី ស្របពេលដែលអាពាហ៍ពិពាហ៍ចាស់មិនទាន់បានរំលាយ នោះពួកគេនឹងប្រឈមនឹងបទល្មើសនៃច្បាប់ស្ដីពីឯកពន្ធភាព[15]។

[11] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥៨

[12] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥៣

[13] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥៤

[14] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៤៩

[15] ច្បាប់ស្ដីពីឯកពន្ធភាពឆ្នាំ២០០៦, មាត្រា៩

### ៧. អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល១២០ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬ លុបចោល។ ប៉ុន្តែករណីនេះមិនអាចអនុវត្តបានឡើយប្រសិនបើនារីនោះមានផ្ទៃពោះនៅមុនពេលដែល អាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ហើយបានសម្រាលកូន ឬ មានការបញ្ជាក់ពីការ គ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត[16]។

ការដែលច្បាប់តម្រូវឲ្យនារីរង់ចាំ១២០ថ្ងៃ ដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មី គឺដើម្បីកំណត់បិតុភាពនៃកូនដែលកើតក្នុងឆ្នាំបន្ទាប់ពីការបញ្ចប់អាពាហ៍ពិពាហ៍លើកមុន។ ប្រសិនបើស្ត្រីនោះឆាប់រៀបអាពាហ៍ពិពាហ៍ពេក ហើយកូនដែលកើតមកក្រោយពេលរៀបអាពាហ៍ពិពាហ៍ថ្មីនោះ ធ្វើឲ្យកើតមានបញ្ហាស្តីពីការកំណត់បិតុភាពរបស់កូននោះថា ជាកូនរបស់ប្តីមុន ឬ ជាកូនរបស់ប្តីក្រោយ។

### ៨. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត

អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយរវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតក្នុងបីថ្នាក់ រាប់ទាំងថ្នាក់ទីបីផងដែរ[17]។

មូលហេតុនៃការហាមឃាត់ក្នុងការរៀបអាពាហ៍ពិពាហ៍ប្រភេទនេះ គឺដោយសារសុជាតិវិជ្ជា និងសីលធម៌សង្គម។ ចំពោះមូលហេតុនៃសុជាតិវិជ្ជា ការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតគ្នាងាយនឹងបណ្តាលឲ្យពន្ធុខ្សោយជាប់គ្នា ហើយលទ្ធភាពដែលកូនកើតមកអាចមានភាពពិការមានអត្រាខ្ពស់[18]។ ឧទាហរណ៍៖ ការរៀបអាពាហ៍ពិពាហ៍រវាងឪពុក ឬ ម្តាយ និងកូន ជីដូនជីតាបង្កើត និងចៅ បងប្អូនបង្កើត និងបងប្អូនបង្កើត -ល-។

### ៩. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុងបីថ្នាក់ រាប់ទាំងថ្នាក់ទីបីផង[19]។

បុរស និងស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នា មិនត្រូវជាប់ចំណងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះបីជានៅថ្នាក់ណាក៏ដោយ។ ទោះបីជាញាតិពន្ធខ្សែផ្ទាល់បានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ដោយ ច្បាប់មិនអនុញ្ញាតឲ្យញាតិពន្ធខ្សែផ្ទាល់នោះ អាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានដែរ។ ឧទាហរណ៍៖ ការរៀបអាពាហ៍ពិពាហ៍រវាង ឪពុក ឬ ម្តាយក្មេក និងកូនប្រសា ជីដូនជីតាក្មេក និងចៅប្រសា បងថ្លៃ និងប្អូនថ្លៃ -ល-។

---

[16] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥០

[17] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥១

[18] សាស្ត្រាចារ្យ ឥន យឿន, ២០១៣. នីតិគ្រួសារ និងអាពាហ៍ពិពាហ៍

[19] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥២

## កថាខណ្ឌ២៖ លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍

### ១. លក្ខខណ្ឌមុនរៀបអាពាហ៍ពិពាហ៍

#### ១.១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

បុរស នារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី[20]។ ភាគីខាងបុរសត្រូវភ្ជាប់នូវឯកសារមួយចំនួននៅពេលដាក់ពាក្យស្នើសុំទៅមន្ត្រីអត្រានុកូលដ្ឋានខាងនារីដូចជា៖

-ត្រូវមានការយល់ព្រមពីឪពុកម្តាយ ឬ អាណាព្យាបាល ចំពោះអនីតិជន

-ភស្តុតាងនៃការរំលាយអាពាហ៍ពិពាហ៍មុនមានដូចជា សាលក្រមលែងលះ សាលក្រមស្តីពីការបាត់ខ្លួន ឬ សំបុត្រមរណភាព ឬ មោឃភាពនៃអាពាហ៍ពិពាហ៍

-សំបុត្របញ្ជាក់ថា បានគោរពវិធវភាព

-ការអនុញ្ញាតក្នុងករណីដែលគូស្រករមានជាប់ញាតិ និងញាតិពន្ធ

-លិខិតបញ្ជាក់ពីមន្ត្រីអត្រានុកូលដ្ឋាន ឬ ពីកន្លែងការងារ ថាខ្លួនពិតជានៅលីវ (លិខិតនេះហៅថា "កិច្ចសន្យាសាមីជនកូនប្រុស កូនស្រី")។

#### ១.២. ការប្រកាសផ្សាយ

##### ១.២.១. គោលបំណង

ការបិទប្រកាសនេះ មានគោលដៅបង្កលទ្ធភាពដល់ជនដែលមានប្រយោជន៍នៅក្នុងរឿងនេះដឹងឮ ហើយអាចប្តឹងទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ព្រម ឬ ក៏ការរៀបអាពាហ៍ពិពាហ៍នោះប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ហើយត្រូវបានច្បាប់ការពារសិទ្ធិ និងផលប្រយោជន៍ទាំងនោះ[21]។

##### ១.២.២. បែបបទប្រកាសផ្សាយ

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលគ្រោងនឹងធ្វើនោះផ្សាយជាសាធារណៈនៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬ សង្កាត់នៃសាមីខ្លួននារីមួយច្បាប់។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬ សង្កាត់ នៃសាមីខ្លួនបុរស១ច្បាប់។

ប័ណ្ណប្រកាសត្រូវចុះ៖

-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅដ្ឋាននៃអនាគតប្តី ប្រពន្ធ។

---

[20] អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០. មាត្រា២៨

[21] សាស្ត្រាចារ្យ អម សុផាណារ៉ាត, ២០១៤-២០១៥. នីតិរដ្ឋប្បវេណី

-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅដ្ឋានរបស់ឪពុក ម្តាយ នៃអនាគតប្តី ប្រពន្ធ បើឪពុក ឬ ម្តាយស្លាប់ ត្រូវដាក់ថាស្លាប់។

-រយៈពេលប្តឹងជំទាស់[22]។

**១.២.៣. រយៈពេលប្រកាសផ្សាយ**

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឲ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់។ បើមានបណ្តឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់[23]។

**២. លក្ខខណ្ឌក្នុងពេលរៀបអាពាហ៍ពិពាហ៍**

**២.១. វត្តមានគូស្រករ**

ជាគោលការណ៍ គូស្រករទាំងពីរត្រូវតែមានវត្តមាននៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍មិនអាចធ្វើទៅបានឡើយ ប្រសិនបើអវត្តមានភាគីបុរស ឬ នារី[24]។

**២.២. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារី ដែលស្ម័គ្រចិត្តទទួលគ្នាជាប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន២នាក់ផង[25]។

**២.៣. សមត្ថកិច្ចមន្ត្រីអត្រានុកូលដ្ឋាន**

ពេលសាមីខ្លួនជាអនាគតប្តី និងប្រពន្ធ មករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឲ្យសាមីខ្លួនប្តី ប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន[26]។

---

[22] អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០, មាត្រា២៩

[23] អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០, មាត្រា២៩

[24] សាស្ត្រាចារ្យ អម សុផាណារ៉ាត, ២០១៤-២០១៥. នីតិរដ្ឋប្បវេណី

[25] អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០, មាត្រា៣០

[26] អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០, មាត្រា៣១

# ជំពូកទី២
# អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស

## ផ្នែកទី១៖ អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស

### កថាខណ្ឌ១៖ ការរៀបអាពាហ៍ពិពាហ៍នៅបរទេស

ការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬ រវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសដែលគូភាគីមានទីលំនៅ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ សំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសនៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ឬ បើប្តី ប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនបានរស់នៅ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ឬ មន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅនូវសំបុត្រអាពាហ៍ពិពាហ៍ថ្មី ឲ្យទៅជននោះយកទៅប្រើប្រាស់[27]។

### កថាខណ្ឌ២៖ ការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា

#### ១. ពលរដ្ឋខ្មែរ-ជនបរទេស ឬ ជនអន្តោប្រវេសន៍

##### ១.១. លក្ខខណ្ឌ

អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬ ជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[28]។

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍[29]។

[27] អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០, មាត្រា៣២

[28] អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០, មាត្រា៣៣

**១.២. ឯកសារ**

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវសំណុំឯកសារ ដូចខាងក្រោម៖

-ពាក្យសុំរៀបអាពាហ៍ពិពាហ៍

-ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជាដែលនៅមានសុពលភាព

-លិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់ខ្លួនជនបរទេស

-លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស

-លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស

-លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស

ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ពីភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយត្រូវមានបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា។

ចំពោះសាមីខ្លួនពលរដ្ឋខ្មែរ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះ ក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍ ដែលខ្លួនរស់នៅដោយមានភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម៖

-ពាក្យសុំរៀបអាពាហ៍ពិពាហ៍

-សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ

-លិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយ ចេញដោយមេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ

-លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

[29] អនុក្រឹត្យលេខ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, ឆ្នាំ ២០០៨, មាត្រា៥

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេសត្រូវដាក់ស្របពេលជាមួយគ្នា ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរដោយអនុវត្តតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន[30]។

### ១.៣. ការពិនិត្យ និងការប្រកាសផ្សាយរបស់មន្ត្រីអត្រានុកូលដ្ឋាន

មន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់មានភារកិច្ចពិនិត្យ និងសម្រេចលើពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនបុរស និងនារី ក្នុងរយៈពេលយ៉ាងយូរ៣ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់។

បន្ទាប់ពីពិនិត្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរស និងនារី បានត្រឹមត្រូវតាមគោលការណ៍ច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនបុរស និងនារី ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់នៃលំនៅដ្ឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល១០ថ្ងៃ នៅស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅលំនៅដ្ឋានអចិន្ត្រៃយ៍ និងនៅសាលាឃុំ-សង្កាត់នៃសាមីខ្លួនពលរដ្ឋខ្មែរ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។ ផុតរយៈពេល១០ថ្ងៃ ប្រសិនបើគ្មានការប្ដឹងតវ៉ា ឬ ប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍បាន[31]។

### ១.៤. ការចុះសំបុត្រអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ-សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន[32]។

---

[30] អនុក្រឹត្យលេខ១៨៣ ស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, ឆ្នាំ ២០០៨, មាត្រា៩

[31] អនុក្រឹត្យលេខ១៨៣ ស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, ឆ្នាំ ២០០៨, មាត្រា១០

[32] អនុក្រឹត្យលេខ១៨៣ ស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, ឆ្នាំ ២០០៨, មាត្រា១១

**២. ជនបរទេស-ជនបរទេស**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬ ជនអន្តោប្រវេសន៍នោះបានដោយអនុវត្តតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ដែលមានចែងក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋានដោយប្រាប់ពីទីកន្លែង និងពេលវេលា ដែលខ្លួនរៀបអាពាហ៍ពិពាហ៍នោះឲ្យបានច្បាស់[33]។

**កថាខណ្ឌ៣៖ ការរំលាយអាពាហ៍ពិពាហ៍**

**១. នៅបរទេស**

ការរំលាយអាពាហ៍ពិពាហ៍ដែលធ្វើនៅបរទេសរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬ រវាងពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅឯបរទេស ត្រូវបានទទួលស្គាល់យកជាការបាននៅប្រទេសកម្ពុជា។

**២. នៅប្រទេសកម្ពុជា**

ការរំលាយអាពាហ៍ពិពាហ៍ដែលធ្វើនៅប្រទេសកម្ពុជារវាងជនបរទេស និងជនបរទេស ឬ រវាងជនបរទេស និងពលរដ្ឋខ្មែរ ត្រូវធ្វើតាមច្បាប់នៃប្រទេសកម្ពុជា។

តុលាការនៃប្រទេសកម្ពុជាមានសមត្ថកិច្ចសម្រេចលើបណ្តឹងសុំរំលាយអាពាហ៍ពិពាហ៍របស់សហព័ទ្ធណាមួយដែលចូលមកតាំងលំនៅដ្ឋាននៅប្រទេសកម្ពុជា[34]។

**ផ្នែកទី២៖ មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍**

**កថាខណ្ឌ១៖ មោឃភាពនៃអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍មួយមានអានុភាពលុះត្រាតែត្រូវបានទទួលស្គាល់ដោយច្បាប់។ ចំពោះអាពាហ៍ពិពាហ៍ដែលកើតឡើងដោយការភាន់ច្រឡំលើមនុស្ស និងដោយការបង្ខំ អាពាហ៍ពិពាហ៍នោះនឹងត្រូវចាត់ទុកជាមោឃៈ[35]។

**១. មោឃភាពដាច់ខាត**

**១.១. ការភាន់ច្រឡំលើមនុស្ស**

ការរៀបអាពាហ៍ពិពាហ៍ដែលអាចប្រព្រឹត្តទៅបាន ដោយរលូនលុះត្រាតែអាពាហ៍ពិពាហ៍នោះកើតឡើងពីឆន្ទៈរបស់គូភាគីទាំងពីរ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍នោះប្រព្រឹត្តទៅដោយការភាន់ច្រឡំនៃឈ្មោះ ឬ រូបរាង ភាគីម្ខាងទៀតអាចសុំមោឃភាពអាពាហ៍ពិពាហ៍នោះបានក្រោយពីខ្លួនបានដឹង[36]។ ប៉ុន្តែភាគីម្ខាងមិនអាចយកមូលហេតុនៃការភាន់ច្រឡំនេះមកធ្វើជាសម្អាងក្នុងការប្តឹងមោឃភាព

[33] អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០, មាត្រា៣៤

[34] សាស្ត្រាចារ្យ អម សុផាណារ៉ាត, ២០១៤-២០១៥. នីតិរដ្ឋវេណី

[35] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥៨

[36] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥៨

អាពាហ៍ពិពាហ៍បាននោះទេ។ ដូចក្នុងករណីដែលភាគីម្ខាងបានគិតថា សហព័ទ្ធរបស់ខ្លួនជាមនុស្សសុភាពរាបសារ តែក្រោយពេលរៀបការរួច សហព័ទ្ធនោះបានផ្លាស់ប្តូរចរិតលក្ខណៈទាំងស្រុង ភាគីម្ខាងនោះមិនអាចដាក់ពាក្យសុំមោឃភាពអាពាហ៍ពិពាហ៍បានឡើយ។

**១.២. ការបង្ខិតបង្ខំ**

ប្រសិនបើភាគីម្ខាងត្រូវបានបង្ខិតបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀតដោយឪពុកម្តាយ ឬ អាណាព្យាបាល ឬ តតិយជន ភាគីនោះអាចដាក់ពាក្យសុំមោឃភាពអាពាហ៍ពិពាហ៍នោះបាន។ អាពាហ៍ពិពាហ៍មួយដែលអាចយកជាការបានលុះត្រាតែអាពាហ៍ពិពាហ៍នោះកើតឡើងដោយភាគីទាំងពីរមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ ការគ្មានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា វាខុសនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។

**២. មោឃភាពមិនដាច់ខាត**

អាពាហ៍ពិពាហ៍មួយនឹងត្រូវបានចាត់ទុកជាមោឃៈក្នុងករណីដែលអាពាហ៍ពិពាហ៍នោះមិនបានបំពេញបែបបទទៅតាមផ្លូវច្បាប់ដូចជា ការមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឬ មិនបានជូនដំណឹងជាសាធារណៈជាដើម។ ប៉ុន្តែ ប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍នោះមិនត្រូវបានរាំងដោយសារហេតុនោះឡើយ។

**២.១. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍**

ប្រសិនបើភាគីមិនដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅឃុំ ឬ សង្កាត់នៃលំនៅដ្ឋានខាងនារីនោះទេ គេអាចប្តឹងសុំមោឃភាពនៃអាពាហ៍ពិពាហ៍នោះបាន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ច្បាប់កម្ពុជាមិនបានចែងច្បាស់អំពីអ្នកមានសិទ្ធិប្តឹងក្នុងករណីនេះទេ។

**២.២. ភាគីមិនបានជូនដំណឹងជាសាធារណៈ**

ប្រសិនបើគូស្រករទាំងពីរបានទទួលការអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ដោយមន្ត្រីអត្រានុកូលដ្ឋានហើយ ប៉ុន្តែភាគីទាំងពីរមិនបានបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍តាមការកំណត់របស់មន្ត្រីអត្រានុកូលដ្ឋាននោះ គេអាចប្តឹងសុំមោឃភាពអាពាហ៍ពិពាហ៍នោះបាន។

**២.៣. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍**

ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួច ប្រសិនបើសហព័ទ្ធទាំងពីរមិនបានទៅឃុំ ឬ សង្កាត់នៃលំនៅដ្ឋានខាងនារីដើម្បីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ សំបុត្រអាពាហ៍ពិពាហ៍ គេអាចប្តឹងសុំមោឃភាពអាពាហ៍ពិពាហ៍នោះបាន។

**២.៤. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍**

ក្នុងករណីដែលសហព័ទ្ធទាំងពីរបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួចហើយនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋាននារី ប៉ុន្តែពួកគេមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ដែលត្រូវចុះនៅក្នុងសៀវភៅអាពាហ៍ពិពាហ៍របស់មន្ត្រីអត្រានុកូលដ្ឋាន គេអាចស្នើសុំប្តឹងមោឃភាពអាពាហ៍ពិពាហ៍នោះបាន។

សរុបមក ទោះបីជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងអំពីមូលហេតុមួយចំនួននៃមោឃភាពក៏ដោយ រាល់មូលហេតុនៃចំណុចមោឃភាពមិនដាច់ខាតនេះ ក្នុងករណីជាក់ស្តែង វាស្ទើរតែគ្មានអានុភាពក្នុងការរារាំងអាពាហ៍ពិពាហ៍នោះឡើយ។

**កថាខណ្ឌ២៖ ការលុបចោលអាពាហ៍ពិពាហ៍**

ការលុបចោលអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងលើគ្រប់អាពាហ៍ពិពាហ៍ដែលផ្ទុយនឹងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ អ្នកដែលមានសិទ្ធិប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍មានដូចជា ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬ តំណាងអយ្យការ។ ប៉ុន្តែ នៅក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាពហើយ តំណាងអយ្យការពុំអាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ[37]។

**១. អាពាហ៍ពិពាហ៍មិនគ្រប់អាយុ**

បុរស និងនារីដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ[38]។ ដូចនេះ រាល់អាពាហ៍ពិពាហ៍ដែលកូនក្រមុំ និងកូនកំលោះមានអាយុក្រោម១៨ឆ្នាំ ពួកគេអាចសុំប្តឹងលុបចោលអាពាហ៍ពិពាហ៍នោះបាន[39]។ ប៉ុន្តែ ប្រសិនបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ពុំអាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ។ ក្នុងករណីនេះដែរ ជននោះក៏នៅតែអាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាននៅក្នុងអំឡុងពេល៣ខែ ចាប់ពីពេលដែលជននោះបានគ្រប់អាយុ[40]។

**២. ទ្វេពន្ធភាព**

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ[41]។ ដូចនេះ ចំពោះ អាពាហ៍ពិពាហ៍ដែលកើតឡើងរវាងជនមានភរិយាហើយ និងជនដែលនៅលីវ អាពាហ៍ពិពាហ៍នោះ នឹងរងនូវការលុបចោល ព្រោះវាជាអាពាហ៍ពិពាហ៍ផ្ទុយច្បាប់[42]។

**៣. អំឡុងពេលរៀបអាពាហ៍ពិពាហ៍ថ្មី**

ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ម្តងទៀតក្នុងពេលមិនទាន់ផុតរយៈពេល១២០ថ្ងៃ ក្រោយពេលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ អាពាហ៍ពិពាហ៍ថ្មីនេះនឹងត្រូវបានលុបចោល[43]។ ប៉ុន្តែក្នុងករណីដែលនារីនោះមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល

[37] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥៩

[38] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥៨

[39] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦០

[40] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦១

[41] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៤៩

[42] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦០

[43] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦២

ហើយបានសម្រាលកូន ឬ មានការបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត ការលុបចោលនឹងមិនមានអានុភាពទៅលើអាពាហ៍ពិពាហ៍ថ្មីនោះឡើយ[44]។

### ៤. ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត

អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយរវាងញាតិលោហិផ្ទាល់ ឬ សាខាញាតិលោហិតក្នុងបីថ្នាក់ រាប់ទាំងថ្នាក់ទីបីផង។ ដូចនេះ ការរៀបអាពាហ៍ពិពាហ៍រវាងឪពុក ឬ ម្តាយ និងកូន បងប្អូនបង្កើត និងបងប្អូនបង្កើត មីង ឬ ពូបង្កើត និងក្មួយ នឹងត្រូវបានលុបចោល[45]។

### ៥. ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុងបីថ្នាក់ រាប់ទាំងថ្នាក់ទីបីផង[46]។ ដូចនេះ រាល់អាពាហ៍ពិពាហ៍ដែលធ្វើឡើងរវាងឪពុក ឬ ម្តាយក្មេក និងកូនប្រសា ជីដូនជីតាក្មេក និងចៅប្រសា បងថ្លៃ និងប្អូនថ្លៃ -ល- នឹងត្រូវបានលុបចោល[47]។

### ៦. ការឆបោក

អាពាហ៍ពិពាហ៍រវាងគូស្រករទាំងពីរដែលកើតឡើងដោយការឆបោករបស់ភាគីណាម្ខាង ឬ តតិយជនដោយមធ្យោបាយឲ្យភាគីម្ខាងទៀតធ្លាក់ទៅក្នុងការភាន់ច្រឡំ ភាគីដែលបានបង្ហាញឆន្ទៈដោយការឆបោកនោះ អាចស្នើទៅតុលាការដើម្បីលុបចោលអាពាហ៍ពិពាហ៍នោះបាន[48]។

សិទ្ធិប្តឹងលុបចោលអាពាហ៍ពិពាហ៍នោះមានត្រឹមតែ៣ខែប៉ុណ្ណោះ ចាប់តាំងពីពេលដែលភាគីបានរកឃើញការឆបោកនោះ។ បើផុតរយៈពេល៣ខែនោះ ភាគីមិនបានប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍នោះ ឬ បានសុខចិត្តទទួលស្គាល់អាពាហ៍ពិពាហ៍ដោយការឆបោកនោះ សិទ្ធិក្នុងការប្តឹងលុបចោលអាពាហ៍ពិពាហ៍របស់ភាគីនោះត្រូវបានរលត់ហើយ[49]។

### ៧. ការគំរាមកំហែង

អាពាហ៍ពិពាហ៍រវាងគូស្រករទាំងពីរដែលកើតឡើងពីការគំរាមកំហែងរបស់ភាគីម្ខាងទៀត ឬ របស់តតិយជនតាមគ្រប់មធ្យោបាយឲ្យភាគីម្ខាងទៀតភិតភ័យ និងសុខចិត្តទទួលយកការរៀបអាពាហ៍ពិពាហ៍ដោយខុសពីឆន្ទៈរបស់ខ្លួន ភាគីដែលបានបង្ហាញឆន្ទៈដោយការគំរាមកំហែងនោះអាចសុំប្តឹងលុបចោលអាពាហ៍ពិពាហ៍នោះបាន[50]។

រយៈពេលនៃការប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍នេះ គឺដូចគ្នានឹងករណីឆបោកផងដែរ។

---

[44] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥០

[45] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦០

[46] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥១

[47] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦០

[48] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៣

[49] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៣

[50] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៣

## ផ្នែកទី៣៖ អានុភាពនៃអាពាហ៍ពិពាហ៍

### កថាខណ្ឌ១៖ សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ

#### ១. ករណីយកិច្ចគោរពគ្នាខាងញាតិ និងការបង្ការអំពើហិង្សាក្នុងគ្រួសារ

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធម្ខាងបានក្លាយជាសមាជិកគ្រួសាររបស់សហព័ទ្ធម្ខាងទៀត។ នេះក៏ជាគោលបំណងនៃអាពាហ៍ពិពាហ៍ផងដែរ ដែលចង់ពង្រីកសង្គមគ្រួសារឲ្យកាន់តែធំ។ ទោះបីជាញាតិរបស់សហព័ទ្ធនោះមិនមែនជាញាតិលោហិតផ្ទាល់របស់សហព័ទ្ធមួយទៀតក៏ដោយ ប៉ុន្តែ សហព័ទ្ធមួយនោះមានករណីយកិច្ចគោរពសិទ្ធិ និងសេរីភាពរបស់សមាជិកគ្រួសារនោះដូចដែលក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានចែងថា "សមាជិកគ្រួសារម្នាក់ៗនៅក្នុងក្រុមគ្រួសារ ត្រូវគោរពសិទ្ធិ និងសេរីភាពរវាងគ្នាទៅវិញទៅមក ហើយត្រូវសង្គ្រោះគ្នាទៅវិញទៅមក។ សមាជិកម្នាក់ៗនៅក្នុងក្រុមគ្រួសារ ត្រូវបង្ការកុំឲ្យកើតមានអំពើហិង្សាក្នុងគ្រួសារ និងត្រូវធ្វើយ៉ាងណាកុំឲ្យកើតមានឡើងនូវការរំលោភសិទ្ធិមនុស្ស[51]។"

#### ២. នាមត្រកូលរបស់ប្ដីប្រពន្ធ

ផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្ដីប្រពន្ធអាចប្រើនាមត្រកូលរបស់ប្ដី ឬប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន[52]។ នៅក្នុងសង្គមជាក់ស្ដែង ការប្រើប្រាស់នាមត្រកូលប្ដីប្រពន្ធ គេសង្កេតឃើញថា ភាគច្រើនមានតែភាគីប្រពន្ធតែប៉ុណ្ណោះដែលយកនាមត្រកូលប្ដីមកប្រើ។ ឧទាហរណ៍៖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលឈ្មោះភរិយារបស់លោកគឺ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**។

#### ៣. ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក

ប្ដីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក[53]។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរមានករណីយកិច្ចរួមរស់ជាមួយគ្នា និងជួយយកអាសាគ្នា ជួយរំលែកទុក្ខធុរៈគ្នាទៅវិញទៅមក ព្រមទាំងផ្ដល់យោបល់ និងចូលរួមដោះស្រាយបញ្ហាទាំងអស់គ្នា។

#### ៤. សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម

ប្ដីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន[54]។ ទោះបីជាបុរស និងស្ត្រីពីរនាក់បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាក៏

[51] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥៣

[52] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៥

[53] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៦

[54] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៧

ដោយ ភាគីទាំងពីរមានសិទ្ធិសេរីភាពក្នុងការប្រកបមុខរបររបស់ខ្លួនបានដដែល។ សហព័ទ្ធម្ខាងមិនអាចបង្ខំឲ្យសហព័ទ្ធម្ខាងទៀតឈប់ប្រកបមុខរបរ ឬ ការងាររបស់គេបាននោះទេ។ លើសពីនេះទៅទៀត សហព័ទ្ធទាំងពីរមានសិទ្ធិសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយរៀងៗខ្លួន ដោយគ្មានសហព័ទ្ធណាអាចបង្ខំឲ្យប្តី ឬ ប្រពន្ធរបស់ខ្លួនមកចូលរួមសកម្មភាពនយោបាយរបស់ខ្លួនបាននោះទេ មានន័យថា សហព័ទ្ធទាំងពីរស្រឡាញ់គណបក្សនយោបាយខុសគ្នាបាន។ ប្តីប្រពន្ធក៏មានសិទ្ធិសេរីភាពក្នុងការគោរពជំនឿ និងសាសនារៀងៗខ្លួនផងដែរ។

**៥. ករណីយកិច្ចចិញ្ចឹមបីបាច់ ថែរក្សា និងអប់រំកូន**

ច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "មាតាបិតាមានកាតព្វកិច្ចចិញ្ចឹម ថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ។ កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ[55]"។ ឪពុកម្តាយដែលបង្កើតកូនហើយមិនអាចបោះបង់ ឬ ទុកកូនចោល ឬ បង្កើត កូនដើម្បីយកកូនធ្វើអាជីវកម្ម (លក់ ឬ ដូរ) ឬ កេងប្រវ័ញ្ចលើកម្លាំងពលកម្មកូនបានឡើយ។ ក្នុងករណី ដែលឪពុកម្តាយបានធ្វើបែបនេះ ពួកគេទាំងពីរនឹងត្រូវទទួលទោសតាមច្បាប់។

**កថាខណ្ឌ២៖ ទំនាក់ទំនងឪពុកម្តាយ និងកូន**

**១. ទំនាក់ទំនងឪពុកម្តាយបង្កើត និងកូនបង្កើត**

**១.១. ករណីយកិច្ចនៃការចុះសំបុត្រកំណើត**

ឪពុក ឬ ម្តាយរបស់កូន ត្រូវចុះកំណើតរបស់កូននៅសាលាឃុំសង្កាត់នៃលំនៅដ្ឋានរបស់ឪពុក ឬ ម្តាយ ក្នុងអំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលកូននោះកើត។ ប្រសិនបើឪពុក ឬ ម្តាយមិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្តាយ ត្រូវសុំចុះកំណើតរបស់កូននោះឲ្យបានឆាប់រហ័ស។

ក្នុងករណីដែលឪពុកម្តាយបានធ្វេសប្រហែសនឹងករណីយកិច្ចដោយគ្មានមូលហេតុត្រឹមត្រូវ ពួកគេនឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី១០.០០០ (មួយម៉ឺន) រៀល[56]។

**១.២. ការសម្រេចអំពីបុត្តភាព**

**១.២.១. មាតុភាព**

ស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន[57]។ ចំណុចនេះដែរចង់បញ្ជាក់អំពីភាពច្បាស់លាស់មួយដែលមិនអាចប្រកែកបាន ហើយមានលក្ខណៈសមហេតុផលបំផុត។ ហើយម្យ៉ាងទៀតចំពោះអង្គហេតុសម្រាលកូននេះ មិនត្រឹមតែអាចកំណត់អំពីចំណាងមាតុភាពដែលកើតដំណាលពេល និងចំណងបុត្តភាពនោះទេ អាចឲ្យគេនឹកឃើញពីចំណងបិតុភាពផងដែរ ចំពោះបុរសដែលមានទំនាក់ទំនងនឹងម្តាយនោះ។

[55] សាស្ត្រាចារ្យ អម សុផាណារ៉ាត, ២០១៤-២០១៥. នីតិរដ្ឋប្បវេណី

[56] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨៥

[57] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨៧

### ១.២.២. បិតុភាព

#### ១.២.២.១. លក្ខខណ្ឌនៃបិតុភាព

ដើម្បីកំណត់ភាពជាឪពុកបានត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

-ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតជាកូនរបស់ប្តី។

-កូនដែលបានកើតនៅក្រោយអំឡុងពេល១៨០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល៣០០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថា មានគភ៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ។

-ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងអំឡុងពេលដែលហាមឃាត់រៀបអាពាហ៍ពិពាហ៍ថ្មី (១២០ថ្ងៃ) បានបង្កើតកូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ កូននោះជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ[58]។

#### ១.២.២.២. ការបដិសេធបិតុភាព

ជនដែលត្រូវបានសន្មតជាឪពុក ឬ កូន អាចបដិសេធបិតុភាពបាន[59]។

សិទ្ធិបដិសេធរបស់ជនដែលត្រូវសន្មតជាឪពុកត្រូវអនុវត្តដោយបណ្តឹងចំពោះកូន។ ជននេះត្រូវដាក់ពាក្យបណ្តឹងបដិសេធបិតុភាពក្នុងអំឡុងពេល៦ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងអំពីកំណើតរបស់កូន។ ក្នុងករណីដែលអំឡុងពេលនេះបានកន្លងផុត បើជនដែលត្រូវសន្មតជាឪពុកជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនាដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ[60]។

ក្រៅពីការបដិសេធបិតុភាពពីជនដែលត្រូវសន្មតជាឪពុកចំពោះកូន កូនក៏មានសិទ្ធិធ្វើបណ្តឹងបដិសេធបិតុភាពចំពោះជនដែលត្រូវសន្មតជាឪពុកនោះបានដែរ។ ក្នុងករណីដែលកូននោះជាអនីតិជនគ្មានម្តាយជាអ្នកអនុវត្តអំណាចមេបា ឬ គ្មានអាណាព្យាបាល តុលាការត្រូវជ្រើសរើសអ្នកតំណាងពិសេស។ មួយវិញទៀតផងដែរ កូនមិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយ ប្រសិនបើអំឡុងពេល៦ខែ បានកន្លងផុត គិតចាប់ពីពេលដែលខ្លួនបានក្លាយជានីតិជន។ ក្នុងករណីដែលអំឡុងពេលនេះបានកន្លងផុត ហើយបើកូននោះជាជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនាដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ[61]។

ការបដិសេធបិតុភាព ត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន[62]។

[58] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៨៨៨

[59] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៨៨៩

[60] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៨៩០

[61] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៨៩១

[62] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៨៩២

### ១.៣. ការទទួលស្គាល់បិតុភាព

#### ១.៣.១. ការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន។ ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ[63]។

#### ១.៣.២. សមត្ថភាពក្នុងការទទួលស្គាល់

ដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ[64]។

#### ១.៣.៣. ការទទួលស្គាល់របស់ឪពុក

##### ១.៣.៣.១. កូនជាអនីតិជន

ឪពុកអាចទទួលស្គាល់កូនជាអនីតិជនបាន។ មិនតែប៉ុណ្ណោះ ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបាន ដោយទទួលការយល់ព្រមពីម្តាយ[65]។

##### ១.៣.៣.២. កូនជានីតិជន និងកូនដែលបានទទួលមរណភាព

ឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជន មិនអាចទទួលស្គាល់បានឡើយ បើគ្មានការយល់ព្រមពីកូន។

ឪពុកអាចទទួលស្គាល់កូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់។ ក្នុងករណីនេះ បើបច្ឆាញាតិផ្ទាល់នោះជានីតិជន ត្រូវទទួលការយល់ព្រមពីជននោះ[66]។

#### ១.៣.៣. ទម្រង់នៃការទទួលស្គាល់

ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន។ ការទទួលស្គាល់ក៏អាចធ្វើតាមមតកសាសន៍ក៏បានដែរ។

ដើម្បីទទួលស្គាល់ទារកនៅក្នុងគភ៌ ជនដែលមានបំណងទទួលស្គាល់ទារកនោះ គឺត្រូវមានការយល់ព្រមពីម្តាយ ហើយម្តាយនៃទារកនោះត្រូវចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ[67]។

#### ១.៣.៤. អានុភាពនៃការចុះកំណើត និងការទទួលស្គាល់

បើបុគ្គលណាម្នាក់បានសុំចុះសំបុត្រកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬ ផ្តិតមេដៃនៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថា បានទទួលស្គាល់កូននោះនៅពេលដែលបានសុំចុះកំណើត[68]។

ឪពុកដែលបានទទួលស្គាល់កូនហើយ ពុំអាចលុបចោលការទទួលស្គាល់នោះបានឡើយ[69]។

---

[63] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៩៣

[64] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៩៤

[65] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៩៥

[66] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៩៦

[67] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៩៧

[68] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៩៨

### ១.៣.៥. បណ្តឹងទាមទារឲ្យទទួលស្គាល់

កូនអាចដាក់ពាក្យបណ្តឹងទាមទារឲ្យទទួលស្គាល់បាន។ ចំពោះកូនដែលជានីតិជន ឬ បច្ឆាញាតិផ្ទាល់របស់កូនដែលបានទទួលមរណភាពនោះមិនបានយល់ព្រម ពួកគេពុំអាចទាមទារឲ្យទទួលស្គាល់បានឡើយ។

ចំពោះកូនដែលបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឲ្យទទួលស្គាល់បាន។

កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឲ្យទទួលស្គាល់បានក្នុងអំឡុងពេល១ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក។ មួយវិញទៀត ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេលដែលបានកំណត់ខាងលើ ត្រូវគណនាគិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះបានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ។

កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងទាមទារឲ្យទទួលស្គាល់បាននៅក្នុងអំឡុងពេល១ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុក នៅក្រោយមរណភាពរបស់ឪពុក។

អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងទាមទារឲ្យទទួលស្គាល់ជំនួសជនទាំងនោះបាន[70]។

### ២. ការសុំកូន

របបសុំកូន គឺជារបបទទួលស្គាល់ឲ្យជនដែលគ្មានទំនាក់ទំនងសាច់ញាតិ បង្កើតនូវទំនាក់ទំនងជាឪពុកម្តាយ និងកូន ដូចឪពុកម្តាយ និងកូនបង្កើតដែរ។

គោលបំណងនៃរបបសុំកូនគឺៈ

-អ្នកដែលគ្មានអ្នកណាស្នង អាចរកអ្នកស្នងបានតាមរយៈការសុំកូន (ឲ្យស្នងអាជីវកម្ម)

-គ្រួសារ សន្តតិកម្ម ទ្រព្យសម្បត្តិ ជាអាទិ៍

-ចំពោះអ្នកដែលគ្មានកូន អាចរកកូនបាន (ដើម្បីឲ្យកូនផ្គត់ផ្គង់អាហារកិច្ចនៅពេលដែលខ្លួនចាស់ជាអាទិ៍)

-រកឪពុកម្តាយសម្រាប់កុមារកំព្រា[71]។

---

[69] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០០០

[70] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០០១

### ២.១. ស្មុំកូនធម្មតា

ស្មុំកូនធម្មតា អាចបង្កើតឡើងតាមរយៈកិច្ចសន្យារវាងភាគីទាំងសងខាង ក្នុងគោលបំណងបង្កើតនូវអានុភាពដូចគ្នានឹងរវាងឪពុកម្ដាយ និងកូនបង្កើតធម្មជាតិ។

#### ២.១.១. លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា

##### ២.១.១.១. លក្ខខណ្ឌគ្រឹះ

ដើម្បីបង្កើតស្មុំកូនធម្មតា ត្រូវគោរពតាមលក្ខខណ្ឌគ្រឹះមួយចំនួនដូចជា៖

-ភាគីមានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន[72]។

-បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី២៥ឆ្នាំឡើងទៅ។ បុគ្គលដែលនឹងក្លាយជាកូនសុំមិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ[73]។

-ជនដែលមានសហព័ទ្ធ ដើម្បីស្មុំកូនជាអនីតិជន ត្រូវដាក់ពាក្យស្មុំកូនជាមួយនឹងសហព័ទ្ធ[74]។

-ជនដែលមានសហព័ទ្ធ ដើម្បីស្មុំកូនធម្មតា ត្រូវមានការយល់ព្រមពីសហព័ទ្ធ[75]។

-បើសិនជាបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន តុលាការទទួលស្គាល់នូវស្មុំកូននេះតែក្នុងករណីដែលមានភាពចាំបាច់ដើម្បីការពារផលប្រយោជន៍របស់អនីតិជននេះប៉ុណ្ណោះ។ បើសិនជាបុគ្គលដែលនឹងក្លាយជាកូនសុំមានអាយុ១៥ឆ្នាំ ឬក៏បើសិនបុគ្គលនោះអាចបង្ហាញឆន្ទៈបាន តុលាការត្រូវសាកសួរមតិរបស់បុគ្គលនោះ[76]។

-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនដាក់ពាក្យសុំឲ្យបង្កើតស្មុំកូន ដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួន មកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅដាក់ពាក្យសុំឲ្យបង្កើតស្មុំកូនដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួនមកធ្វើជាកូនសុំ តុលាការអាចបង្កើតស្មុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និងការគ្រប់គ្រងទ្រព្យសម្បត្តិ[77]។

---

[71] ក្រមរដ្ឋប្បវេណីភាគ១ដល់៦, បោះពុម្ពឆ្នាំ២០១២

[72] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២៣

[73] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២០

[74] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២១

[75] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២២

[76] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២៤

[77] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២៥

**២.១.១.២. លក្ខខណ្ឌនីតិវិធី**

ដើម្បីបង្កើតស្មុំកូនធម្មតា បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ត្រូវដាក់ពាក្យសុំទៅតុលាការ ហើយតុលាការនឹងចេញដីកាសម្រេចអំពីការស្មុំកូននោះ។

**២.១.២. អានុភាពនៃស្មុំកូនធម្មតា**

ទោះបីជាមានការបង្កើតស្មុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនស្មុំ និងឪពុកម្តាយបង្កើតត្រូវបន្តអត្ថិភាព ហើយកូនសុំ និងឪពុកម្តាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក។ កូនសុំ និងឪពុកម្តាយបង្កើត មានសិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច[78]។

ដោយបង្កើតស្មុំកូនធម្មតា កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និងត្រូវទទួលបាននូវសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត នៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម។ កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនស្មុំកូនបាន។ ក្នុងករណីដែលកូនសុំជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្តាយចិញ្ចឹម និងសហព័ទ្ធនោះ[79]។

ប្រសិនបើបានបង្កើតស្មុំកូនធម្មតា ត្រូវសរសេរការបង្កើតស្មុំកូនធម្មតានៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ[80]។

**២.១.៣. ការកាត់កាល់ស្មុំកូនធម្មតា**

**២.១.៣.១. លក្ខខណ្ឌនៃការកាត់កាល់តាមការព្រមព្រៀង**

ការកាត់កាល់តាមការព្រមព្រៀង គឺជាការកាត់កាល់ដែលភាគីទាំងសងខាង (ឪពុកម្តាយចិញ្ចឹម និងកូនសុំ) បានព្រមព្រៀង ហើយបានដាក់ពាក្យសុំទៅតុលាការ។ ក្នុងករណីដែលបានពិនិត្យទៅឃើញថា ភាគីទាំងសងខាងមានឆន្ទៈពិតប្រាកដចង់រំលាយ ចោលនូវទំនាក់ទំនងជាឪពុកម្តាយ និងកូនសុំនោះ តុលាការត្រូវសម្រេចឲ្យកាត់កាល់[81]។

**២.១.៣.២. លក្ខខណ្ឌនៃការកាត់កាល់តាមផ្លូវតុលាការ**

ការកាត់កាល់តាមផ្លូវតុលាការ គឺជាការកាត់កាល់ដែលពុំមានការព្រមព្រៀងរវាងភាគីស្តីពីការកាត់កាល់ ហើយភាគីណាម្ខាងបានដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់ភាគីម្ខាងទៀត ហើយតុលាការបានចេញសាលក្រមកាត់កាល់។

---

[78] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២៦

[79] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២៧

[80] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៣

[81] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០២៨

ការកាត់កាល់នោះ គឺជាការកាត់កាល់ដោយបង្ខំចំពោះភាគីម្ខាងទៀត ដែលគ្មានបំណងចង់កាត់កាល់ ដូច្នេះទាល់តែមានមូលហេតុធ្ងន់ធ្ងរ ទើបអាចទទួលស្គាល់បាន។ មូលហេតុដែលនាំឲ្យមានការកាត់កាល់នេះមានដូចជា៖

-បើត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀតដោយទុច្ចរិត

-បើមិនច្បាស់ក្នុងអំឡុងពេលយ៉ាងតិច១ឆ្នាំថា ភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព

-បើមានហេតុធ្ងន់ធ្ងរផ្សេងៗទៀត ដែលបណ្តាលឲ្យមានការពិបាកក្នុងការបន្តសុំកូន។

ទោះបីជាមានមូលហេតុខាងលើកើតឡើងក៏ដោយ ប្រសិនបើកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្តាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្តឹងចំពោះកូនសុំនោះបានឡើយ។ ប៉ុន្តែចំពោះកូនសុំដែលជាអនីតិជននោះមានបំណងចង់ប្តឹងទាមទារឲ្យចេញសាលក្រមកាត់កាល់ ពាក្យសុំនោះត្រូវធ្វើឡើងដោយបុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់។ បើកូនសុំនោះបានដល់អាយុ១៥ឆ្នាំហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ។ ទោះបីជាកូនសុំនោះមិនទាន់ដល់អាយុ១៥ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ[82]។

### ២.១.៤. អានុភាពនៃការកាត់កាល់

អានុភាពទាំងឡាយនៃសុំកូនត្រូវបានបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់។ ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន[83]។

## ២.២. សុំកូនពេញលេញ

សុំកូនពេញលេញ គឺជារបបសម្រាប់ផ្តល់នូវគ្រួសាររមនាមួយចំពោះកុមារអភ័ព្វ ក្នុងគោលបំណងចិញ្ចឹមកូននោះឲ្យមានសុខភាពល្អ ហើយដែលជារបបមួយប្រហាក់ប្រហែលនឹងឪពុកម្តាយបង្កើត ជាងកូនសុំធម្មតា[84]។

### ២.២.១. លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ

#### ២.២.១.១. លក្ខខណ្ឌគ្រឹះ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវគោរពតាមលក្ខខណ្ឌគ្រឹះមួយចំនួនដូចជា៖

-បុគ្គលដែលអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ។ ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀតមិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម។ ប៉ុន្តែ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត មិនចាំបាច់គោរពលក្ខខណ្ឌខាងលើឡើយ[85]។

---

[82] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣១

[83] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣២

[84] ក្រមរដ្ឋប្បវេណីភាគ១ដល់៦, បោះពុម្ពឆ្នាំ២០១២

[85] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០០៨

-ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី២៥ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច២០ឆ្នាំ[86]។

-ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង៨ឆ្នាំ[87]។

-ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដែលនឹងក្លាយជាកូនសុំនោះ។ ចំពោះករណីដែលឪពុកម្តាយនោះមិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំយ៉ាងធ្ងន់ធ្ងរ ការបង្កើតស្មុំកូនពេញលេញនេះមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យបាលសម្រាប់អនីតិជនរបស់កុមារដែលនឹងក្លាយជាកូនសុំនោះឡើយ[88]។

-ប្រសិនបើមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូននោះ[89]។

-ឪពុកម្តាយចិញ្ចឹមត្រូវធ្វើការសាកល្បងក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំនោះយ៉ាងតិច៦ខែ ដោយមានការត្រួតពិនិត្យពីតុលាការ[90]។

**២.២.១.២. លក្ខខណ្ឌទម្រង់**

ដើម្បីបង្កើតស្មុំកូនពេញលេញ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ត្រូវដាក់ពាក្យសុំទៅតុលាការ ហើយតុលាការនឹងចេញដីកាសម្រេចអំពីការស្មុំកូននោះ។

**២.២.២. អានុភាពនៃស្មុំពេញលេញ**

ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ត្រូវបញ្ចប់ដោយស្មុំកូនពេញលេញ[91]។

កូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និងត្រូវទទួលនូវសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត នៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម។ កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលរបស់ស្មុំកូនបាន។ កូនសុំត្រូវស្ថិតនៅក្រោម

---

[86] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០០៩
[87] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១០
[88] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១១
[89] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១២
[90] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៣
[91] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៤

អំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម។ ប៉ុន្តែនៅក្នុងករណីដែលប្ដីប្រពន្ធណាម្ខាងក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹមរបស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្ដាយបង្កើត និងឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម[92]។

### ២.២.៣. ការកាត់កាល់សុំកូនពេញលេញ

បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្ដាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ៖

-បើមានការធ្វើបាបពីឪពុកម្ដាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ

-បើឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។

បើគ្មានមូលហេតុដូចបានបញ្ជាក់ខាងលើទេ ការកាត់កាល់ពុំអាចធ្វើបានឡើយ[93]។

#### ២.២.៣.១. អានុភាពនៃការកាត់កាល់

ញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ដោយកូនសុំកូនពេញលេញ ត្រូវកើតឡើងវិញគិតចាប់ពីថ្ងៃកាត់កាល់[94]។

## កថាខណ្ឌ៣៖ ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ

ក្រោយពេលដែលសហព័ទ្ធទាំងពីរបានក្លាយជាប្ដីប្រពន្ធស្របច្បាប់ ពួកគេទាំងពីរអាចជ្រើសរើសប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ពួកគេដូចដែលក្រមរដ្ឋប្បវេណីបានចែង (ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់) ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដែលពួកគេរកបាន ព្រមទាំងជៀសវាងជម្លោះដែលកើតឡើងដោយសារទ្រព្យ។

### ១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

ប្ដីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែកិច្ចសន្យានេះមិនអាចផ្ទុយនឹងបញ្ញត្តិស្ដីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបានឡើយ[95]។ ការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺដើម្បីកំណត់នូវសិទ្ធិ និងកាតព្វកិច្ចលើទ្រព្យសម្បត្តិដែលប្ដីប្រពន្ធបានកំណត់នៅមុន ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ និងដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលមានការលែងលះគ្នា។

---

[92] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៥

[93] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៦

[94] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៧

[95] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៩

ការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ហើយត្រូវធ្វើនៅក្រសួងយុត្តិធម៌។ កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺត្រូវបានទាមទារឲ្យចុះបញ្ជី។ ប្រសិនបើមិនបានចុះបញ្ជីទេ ប្ដីប្រពន្ធមិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ[96]។

ក្នុងករណីដែលប្ដីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងប្រព័ន្ធទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់[97]។

### ២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ គឺជាប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់តម្រូវឲ្យភាគីប្ដីប្រពន្ធអនុវត្ត ប្រសិនបើពួកគេមិនបានជ្រើសរើសអនុវត្តប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់ បានបែងចែកទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធជា២គឺ ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។

#### ២.១. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធ៖

-មាននៅមុនពេលរៀបអាពាហ៍ពិពាហ៍

-ទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និង

-ជាទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ខាងលើ[98]។

សហព័ទ្ធទាំងពីរអាចប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនបានដោយសេរីដោយពុំចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀត។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន[99]។

#### ២.២. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍[100]។ ទ្រព្យសម្បត្តិរួម គឺចង់សំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយណាដែលប្ដីប្រពន្ធរកបានដូចជា ប្រាក់ខែរបស់ប្ដី ឬ ប្រពន្ធ និងចំណូលពីការរកស៊ីរបស់ប្ដី ឬ ប្រពន្ធ ជាដើម។

[96] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧០

[97] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៩

[98] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧២

[99] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៤

[100] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៣

## ៣. ការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ

### ៣.១. ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម[101]។ ការប្រើប្រាស់ទ្រព្យសម្បត្តិរួម គឺមិនចាំបាច់មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេដូចជា ការប្រើប្រាស់ម៉ូតូ ឬ ឡានជាដើម។ ប៉ុន្តែសហព័ទ្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួមនៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។ ការប្រើប្រាស់ទ្រព្យសម្បត្តិរួម គឺមិនត្រូវលើសពីតម្រូវការចាំបាច់នៅក្នុងជីវភាពប្រចាំថ្ងៃដូចជា ការទិញម្ហូបអាហារប្រចាំថ្ងៃ ការទិញសម្លៀកបំពាក់ ឬ ការផ្គត់ផ្គង់តម្រូវការរបស់កូន។

សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា។ សហព័ទ្ធម្ខាងអាចទាមទារឲ្យភាគីម្ខាងទៀត ឲ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និងរក្សានូវទ្រព្យសម្បត្តិរួមបាន។ បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនសម្រេចបាន ឬ បើពុំអាចពិភាក្សាបាន ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឲ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។

### ៣.២. ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ដូចខាងក្រោម៖

-សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាលថែទាំកូន ជាអាទិ៍

-កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬ ប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និងករណីយកិច្ចផ្សេងទៀតដែលប្តី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្រពន្ធ ឬ ប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

-សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម[102]។

ក្នុងករណីដែលភាគីម្ខាងបានជាប់បំណុលគេដោយគ្មានការយល់ព្រមពីភាគីម្ខាងទៀត ដើម្បីយកទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់ភាគីតែម្ខាងនោះ ភាគីដែលបានជាប់បំណុលគេនោះត្រូវទទួលខុសត្រូវតែម្នាក់ឯង។ ប៉ុន្តែក្នុងករណីដែលភាគីតែម្ខាងបានជំពាក់បំណុលគេ ហើយមិនមានការដឹងឮពីភាគីម្ខាងទៀត ហើយយកបំណុលនោះមកប្រើប្រាស់ក្នុងជីវភាពគ្រួសាររួម សហព័ទ្ធម្ខាងទៀតដែលមិនបានដឹងនោះក៏ចូលរួមទទួលខុសត្រូវផងដែរ។

---

[101] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៤

[102] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៥

### ៣.៣. ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ

បើគ្មានការយល់ព្រមពីប្ដីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធមិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។ ប៉ុន្តែ ក្នុងករណីមានស្ថានភាពមិនអាចជៀសវាងបានសម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីរក្សាជីវភាពរស់នៅ នោះប្ដីប្រពន្ធណាម្ខាងអាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ។

ក្នុងករណីដែលប្ដី ឬ ប្រពន្ធណាម្ខាងបានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និងគ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រមអាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាននៅក្នុងអំឡុងពេល២ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាអចលនវត្ថុ និងនៅក្នុងអំឡុងពេល១ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាទ្រព្យសម្បត្តិផ្សេង[103]។

### ៤. ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

ការអាស្រ័យនៅរបស់សហព័ទ្ធម្ខាងលើទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ឬ អាចនិយាយបានថា សហព័ទ្ធម្ខាងទៅរស់នៅផ្ទះរបស់សហព័ទ្ធម្ខាងទៀត ផ្ទះ ឬ លំនៅដ្ឋាននោះត្រូវបានចាត់ទុកជាលំនៅដ្ឋានគ្រួសារ[104]។ ដូចនេះ ក្នុងករណីដែលសហព័ទ្ធម្ខាងចង់ធ្វើការលក់ ឬ ដូរលំនៅដ្ឋានគ្រួសារមួយនោះ គឺត្រូវមានការព្រមព្រៀងពីភាគីម្ខាងទៀត។ ក្នុងករណីនេះដែរ ប្រសិនបើសហព័ទ្ធម្ខាងបានលក់ ឬ ដូរលំនៅដ្ឋានគ្រួសារនេះហើយ តែបានទិញ ឬ ជួលផ្ទះដើម្បីធ្វើជាលំនៅដ្ឋានគ្រួសារបន្ទាប់ នោះសហព័ទ្ធម្ខាងនោះមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតឡើយ។ ប៉ុន្តែ ប្រសិនបើសហព័ទ្ធម្ខាងនោះបានលក់ ឬ ដូរលំនៅដ្ឋានគ្រួសារនោះហើយ ហើយមិនបានទិញ ឬ ជួលផ្ទះថ្មី ព្រមទាំងមិនបានសុំការអនុញ្ញាតពីភាគីម្ខាងទៀតដើម្បីលក់ ឬ ដូរនោះទេ សហព័ទ្ធម្ខាងទៀតអាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដដែល។

103 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៦

104 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៧

# ជំពូកទី៣
# អំពីការលែងលះ

## ផ្នែកទី១៖ សញ្ញាណនៃការលែងលះ

### កថាខណ្ឌ១៖ មូលហេតុនៃការលែងលះ

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវសិទ្ធិ និងសេរីភាពរបស់បុគ្គលម្នាក់ៗក្នុងការជ្រើសរើសគូស្រករ សិទ្ធិសេរីភាព កាតព្វកិច្ច និងករណីយកិច្ចរបស់សហព័ទ្ធទាំងពីរក្នុងគោលបំណងរក្សាចំណងអាពាហ៍ពិពាហ៍ឲ្យបានគង់វង្សស្ថិតស្ថេរ។ ប៉ុន្តែដោយមានជនខិលខូចមួយចំនួន ដើម្បីគេងចំណេញផលប្រយោជន៍ណាមួយពីសហព័ទ្ធម្ខាងទៀតក្រោយពេលរៀបអាពាហ៍ពិពាហ៍ ពួកគេតែងតែរកមូលហេតុនានាដើម្បីធ្វើការលែងលះ។ ការលែងលះដោយគ្មានមូលហេតុត្រឹមត្រូវនេះបានធ្វើឲ្យជនខិលខូចទាំងនេះរួចផុតពីការទទួលខុសត្រូវក្នុងនាមជាឪពុក ជាម្ដាយ នៅពេលដែលសហព័ទ្ធទាំងពីរមានកូន។ កូនរបស់ពួកគេបានក្លាយជាជនរងគ្រោះដោយផ្ទាល់ដូចជាក្លាយជាក្មេងកំព្រាឪពុក ឬ ម្ដាយ កង្វះអាហារកិច្ច និងការបីបាច់ថែរក្សាពីឪពុកម្ដាយ។ ពួកគេនឹងអាចប្រឈមនឹងការខ្វះភាពកក់ក្ដៅពីក្រុមគ្រួសារ។ ដោយសារកត្តាអវិជ្ជមានទាំងនេះហើយ ទើបច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ (ត្រូវបាននិរាករណ៍) ហើយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់យ៉ាងច្បាស់លាស់នូវមូលហេតុមួយចំនួននៃការលែងលះ។ មូលហេតុទាំងនោះមានដូចជា[105]៖

**១. បានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ**

អំពើផិត គឺជាការរួមសេវនកិច្ចរវាងបុរសដែល មានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្ដីរបស់ខ្លួន[106]។ ការប្រព្រឹត្តអំពើផិតនេះ គឺជាមូលហេតុដ៏ចម្បងមួយនៃការលែងលះក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ព្រោះវាអាចបំផ្លាញនូវមនោសញ្ចេតនារវាងសហព័ទ្ធទាំងពីរដែលបានកសាងជាមួយគ្នាជាច្រើនឆ្នាំក្នុងរយៈពេលតែមួយពព្រិចភ្នែក។

**២. បានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ**

ការមិនបានផ្ដល់មូលហេតុត្រឹមត្រូវក្នុងការចុះចោលផ្ទះ ឬ បោះបង់សហព័ទ្ធម្ខាងទៀតដោយចេតនាក្នុងរយៈពេលមួយយ៉ាងយូរ សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីសុំលែងលះបាន។ ការបោះបង់នេះ គឺសំដៅដល់បំណងរបស់សហព័ទ្ធម្ខាងដែលចង់រួចផុតពីការទទួលខុស

---

[105] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៨

[106] ច្បាប់ស្ដីពីឯកពន្ធភាពឆ្នាំ២០០៦, មាត្រា៧

ត្រូវទៅលើសហព័ទ្ធម្ខាងទៀត ឬ ក្រុមគ្រួសារដូចជាកូនជាដើម។ ទោះជាយ៉ាងណា មូលហេតុមួយចំនួនដូចជា ការទៅបន្តការសិក្សានៅក្រៅប្រទេស ការជាប់កាតព្វកិច្ចយោធា និងការទៅរកស៊ីឆ្ងាយមិនអាចក្លាយជាមូលហេតុមិនត្រឹមត្រូវក្នុងការបោះបង់សហព័ទ្ធម្ខាងទៀតនោះទេ។

**៣. មិនបានដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ**

ក្នុងករណីដែលសហព័ទ្ធម្ខាងបានចុះចោលផ្ទះ ឬ ចាកចេញពីសហព័ទ្ធម្ខាងទៀត និងក្រុមគ្រួសារ ហើយមិនបានត្រឡប់មកវិញ ឬ ជូនដំណឹងទៅសហព័ទ្ធម្ខាងទៀតក្នុងរយៈពេល១ឆ្នាំ សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យទៅតុលាការសុំប្តឹងលែងលះបាន។ ប៉ុន្តែប្រសិនបើការចុះចោលផ្ទះ ឬ ការរស់នៅបែកគ្នាក្នុងរយៈពេល១ឆ្នាំដោយមានការព្រមព្រៀងពីសហព័ទ្ធម្ខាងទៀត នោះមូលហេតុនេះមិនអាចយកជាមូលហេតុនៃការសុំលែងលះបាននោះទេ។ មួយវិញទៀតផងដែរ ទោះបីជាសហព័ទ្ធម្ខាងទៀតបានស្គាល់ទីកន្លែងស្នាក់នៅថ្មីរបស់សហព័ទ្ធមួយនេះ ប៉ុន្តែសហព័ទ្ធមួយនេះមិនមានបំណងវិលត្រឡប់មករស់នៅជាមួយខ្លួនវិញ នោះសហព័ទ្ធម្ខាងទៀតអាចប្តឹងសុំលែងលះបានដូចករណីខាងលើផងដែរ។ ក្នុងករណីដែលមិនបានដឹងអំពីវត្តមានរបស់សហព័ទ្ធម្ខាងទៀតថាស្លាប់ ឬ រស់ក្នុងរយៈពេល១ឆ្នាំ សហព័ទ្ធម្ខាងទៀតមិនអាចដាក់ពាក្យសុំលែងលះបានតែម្តងនោះទេ ប៉ុន្តែត្រូវដាក់ពាក្យសុំតុលាការចេញសាលក្រមស្តីពីការបាត់ខ្លួន ហើយសាលក្រមនេះមានរយៈ១៥ថ្ងៃសម្រាប់ប្តឹងទាស់។ នៅពេលដែលរយៈពេលនេះផុតទៅហើយទើបសហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យសុំលែងលះបាន។ ក្នុងរយៈពេលផុតកំណត់ខាងលើ ទោះបីជាសហព័ទ្ធដែលបានបាត់ខ្លួនត្រឡប់មកវិញក៏ដោយ សហព័ទ្ធមួយនេះមិនអាចដាក់ពាក្យសុំទៅតុលាការឲ្យមោឃភាព ឬ លុបចោលសាលក្រមដែលបានចូលជាស្ថាពរនោះបានឡើយ។

**៤. សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍**

គោលបំណងនៃអាពាហ៍ពិពាហ៍ គឺចង់ឲ្យសហព័ទ្ធទាំងពីររស់នៅជាមួយគ្នាក្នុងលំនៅសង្វាសរួមគ្នា ថែរក្សាគ្នាទៅវិញទៅមក និងស្រឡាញ់គ្នារហូតដល់ចាស់កោងខ្នង។ ប៉ុន្តែគូស្វាមី-ភរិយាទាំងអស់មិនអាចបំពេញគោលបំណងនេះបានទាំងអស់នោះទេ ពីព្រោះក្នុងគ្រួសារខ្លះ ភាគីបុរសដែលជាស្វាមីត្រូវចាកចេញពីភរិយា និងក្រុមគ្រួសារជាច្រើនខែដើម្បីស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។ ប៉ុន្តែនេះមិនមែនជាមូលហេតុនៃការលែងលះនោះទេ។ មូលហេតុដែលសហព័ទ្ធទាំងពីរឈានដល់ការលែងលះ គឺដោយសារសហព័ទ្ធទាំងពីរតែងតែមានជម្លោះនឹងគ្នា ហើយបានរស់នៅបែកគ្នាក្រោយពីពេលមានជម្លោះនោះជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ។ ការរស់នៅបែកគ្នាប្រភេទនេះ គឺមានភាពផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍។ ក្នុងករណីនេះ សហព័ទ្ធម្ខាងអាចដាក់ពាក្យសុំលែងលះពីសហព័ទ្ធម្ខាងទៀតបាន។

### ៥. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមនឹងអាចបដិសានឡើងវិញបាន

មានករណីជាច្រើនផ្សេងទៀតដែលជាកត្តាឈានទៅដល់ការលែងលះផងដែរ។ ករណីទាំងនោះមានដូចជា៖

-អពលានុភាពនៃលិង្គ៖ ចាប់តាំងពីច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ចូលជាធរមាន និងបានយកមកអនុវត្តរហូតដល់ឆ្នាំ២០០៧ ហើយត្រូវបាននិរាករណ៍ដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្នុងរយៈពេលខាងលើនេះ បុរសគ្មានពលានុភាពនៃលិង្គមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ[107]។ ប៉ុន្តែក្រោយមក យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មូលហេតុនេះមិនមានអានុភាពទៀតឡើយ។ គូស្រករទាំងសងខាងអាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍បាន ទោះបីជាបានដឹងហើយថាភាគីខាងបុរសគ្មានពលានុភាពនៃលិង្គក៏ដោយ ពីព្រោះគោលបំណងចម្បងនៃអាពាហ៍ពិពាហ៍ គឺការស្រឡាញ់ ថែរក្សា និងចង់រួមរស់ជាមួយគ្នាជារៀងរហូត។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មូលហេតុនេះក៏នៅបន្តមានវត្តមាននៅក្នុងការលែងលះរបស់គូស្រករក្នុងពេលបច្ចុប្បន្ន ពីព្រោះភាគីម្ខាងមិនអាចបំពេញសេចក្តីត្រូវការរបស់ភាគីម្ខាងទៀត ដែលនាំឲ្យគ្មានសុភមង្គលក្នុងគ្រួសារ ដូចនេះ ភាគីម្ខាងទៀតដាក់ពាក្យសុំលែងលះ។ នេះជាច្បាប់ធម្មជាតិដែលតម្រូវឲ្យបុរស និងស្ត្រីត្រូវរួមដំណេកជាមួយគ្នាក្រោយពេលរៀបអាពាហ៍ពិពាហ៍ ហើយវាក៏ជាគោលបំណងដ៏ចម្បងនៃការរៀបអាពាហ៍ពិពាហ៍ផងដែរដើម្បីមានកូនចៅនៅថ្ងៃក្រោយ។

-ការធ្វើទារុណកម្មដល់រូបកាយ និងផ្លូវចិត្តទៅលើសហព័ទ្ធម្ខាង៖ ក្នុងករណីដែលសហព័ទ្ធម្ខាងបានវាយដំច្រំធាក់ វាយធ្វើបាប និងធ្វើបាបផ្លូវចិត្តទៅលើសហព័ទ្ធម្ខាងទៀត សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យសុំលែងលះបាន។ នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន មូលហេតុនេះ គឺជាមូលហេតុដ៏ចម្បងនៃការលែងលះ។ មួយវិញទៀតផងដែរ ក្នុងករណីដែលសហព័ទ្ធម្ខាងបានធ្វើការជេរប្រមាថមើលងាយប្រើប្រាស់ពាក្យសម្តីមិនគួរសម រួមទាំងកាយវិការគ្មានសីលធម៌ទៅលើក្រុមគ្រួសារ ឬ ញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀតដោយគ្មានការកោតក្រែង ដែលអាចធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយស សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យសុំប្តឹងលែងលះបានផងដែរ។

-អាកប្បកិរិយាគ្មានគុណធម៌ ឬ មារយាទមិនល្អ៖ ក្នុងករណីដែលសហព័ទ្ធម្ខាងបានប្រព្រឹត្តអំពើអបាយមុខផ្សេងៗដូចជា ការលេងល្បែងស៊ីសង ប្រើប្រាស់គ្រឿងញៀន និងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដើម្បីរួចផុតពីការពាក់ព័ន្ធ និងពុំអាចទ្រាំទ្រនូវទង្វើរបស់សហព័ទ្ធមួយនេះបាន សហព័ទ្ធនោះអាចដាក់ពាក្យសុំប្តឹងលែងលះទៅតុលាការបានគ្រប់ពេល។

---

[107] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩, មាត្រា៦

**កថាខណ្ឌ២៖ មូលហេតុរារាំងនៃការលែងលះ**

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កាលបើតុលាការយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូន ក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារការលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។ មួយវិញទៀតផងដែរ ក្នុងមូលហេតុពីរខាងលើដូចជា សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនឹងបំណងនៃអាពាហ៍ពិពាហ៍ និងករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន កាលបើតុលាការយល់ថា ការទាមទារលែងលះរបស់សហព័ទ្ធនោះផ្ទុយនឹងភាពសុចរិតដោយបានធ្វើប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិការ និងជួយសង្គ្រោះចំពោះសហព័ទ្ធម្ខាងទៀត តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះបានដោយឆន្ទានុសិទ្ធិរបស់ខ្លួន[108]។

**កថាខណ្ឌ៣៖ លក្ខខណ្ឌនៃការលែងលះ**

**១. ការលែងលះដោយឯកតោភាគី**

ការលែងលះដោយឯកតោភាគីមានន័យថា សហព័ទ្ធម្ខាងអាចធ្វើការប្តឹងសុំលែងលះសហព័ទ្ធម្ខាងទៀតបានដោយមិនចាំបាច់មានការព្រមព្រៀងពីសហព័ទ្ធដែលត្រូវបានប្តឹងនោះ ទោះបីជាភាគីសហព័ទ្ធមួយនេះរកឃើញ ឬ មិនឃើញកំហុសរបស់សហព័ទ្ធម្ខាងទៀតក៏ដោយ។ សហព័ទ្ធម្ខាងអាចដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីសុំលែងលះដោយយល់ឃើញថា ខ្លួនមិនអាចបន្តជីវិតជាស្វាមី ឬ ជាប្រពន្ធបន្តទៀតបាន។ ការលែងលះដោយឯកតោភាគីនេះ គឺត្រូវពិនិត្យទៅលើធាតុផ្សំសំខាន់ៗ ២គឺ ការលែងលះដោយកំហុស និងការលែងលះដោយឥតកំហុស។

**១.១. ការលែងលះដោយកំហុស**

ក្នុងករណីដែលសហព័ទ្ធម្ខាងបានប្រព្រឹត្តកំហុសយ៉ាងធ្ងន់ធ្ងរដែលសហព័ទ្ធម្ខាងទៀតមិនអាចទទួលយកបាន ហើយកំហុសទាំងនោះត្រូវបានចែងយ៉ាងច្បាស់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យសុំលែងលះបាន ដោយបញ្ជាក់ពីកំហុសរបស់សហព័ទ្ធមួយនោះឲ្យបានច្បាស់លាស់ទៅកាន់តុលាការ។

**១.២. ការលែងលះដោយឥតកំហុស**

ការលែងលះដោយឥតកំហុស គឺផ្អែកលើសញ្ញាណទំនើបនៃសុភមង្គលផ្ទាល់ខ្លួនច្រើនជាងការលែងលះគ្នាដោយផ្អែកលើកំហុស។ គំនិតមួយនៅពីខាងក្រោយការលែងលះគ្នាដោយឥតកំហុស គឺថា មនុស្សត្រូវតែមានសេរីភាពក្នុងការបញ្ចប់ទំនាក់ទំនងដែលលែងជាប្រភពនៃការពេញចិត្តផ្ទាល់

[108] សាស្ត្រាចារ្យ ឥន យឿន, ២០១៣. នីតិគ្រួសារ និងអាពាហ៍ពិពាហ៍

ខ្លួនតទៅទៀត។ ការលែងលះដោយឥតកំហុសនេះក៏ត្រូវផ្អែកលើទស្សនៈដែលថា ប្រសិនបើសហព័ទ្ធម្នាក់ពិតជាមានបំណងលែងលះមែន វាពុំមែនជាការល្អទេក្នុងការបង្ខំឲ្យសហព័ទ្ធនោះឲ្យនៅរក្សាចំណងអាពាហ៍ពិពាហ៍[109]។

ការលែងលះដោយឥតកំហុស សហព័ទ្ធម្ខាងមិនចាំបាច់ខិតខំស្វែងរកកំហុសរបស់សហព័ទ្ធម្ខាងទៀតនោះទេ គឺគ្រាន់តែបង្ហាញឆន្ទៈ ឬ បំណងរបស់ខ្លួនក្នុងការចង់បញ្ចប់ចំណងអាពាហ៍ពិពាហ៍ វាជាមូលហេតុគ្រប់គ្រាន់បាត់ទៅហើយ។

**២. ការលែងលះដោយការព្រមព្រៀង**

ការលែងលះដោយការព្រមព្រៀង គឺចង់បង្ហាញថា សហព័ទ្ធទាំងពីរមានឆន្ទៈ ឬ បំណងក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេ។ ក្រោយពីការសម្រេចចិត្តថានឹងផ្តាច់ចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរអាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន បើបំណងផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេនៅតែមាន។ ពិតណាស់ វាជាសេរីភាពរបស់បុគ្គលក្នុងការជ្រើសរើសផ្លូវដើររបស់ពួកគេ ប្រសិនបើសហព័ទ្ធទាំងពីរមានបំណងចង់លែងលះហើយ ការបង្ខិតបង្ខំឲ្យពួកគេទាំងពីររក្សាចំណងអាពាហ៍ពិពាហ៍ក៏គ្មានតម្លៃដែរ។ ការលែងលះដោយការព្រមព្រៀងកើតឡើងនៅពេលដែលសហព័ទ្ធទាំងពីរបានអស់អារម្មណ៍មនោសញ្ចេតនាជាមួយគ្នា (លែងស្រឡាញ់គ្នា) ហើយចង់លែងលះគ្នា ដោយការលែងលះនេះមិនមែនជាកំហុសរបស់ភាគីខាងណាឡើយ[110]។

**កថាខណ្ឌ៤៖ នីតិវិធីនៃការលែងលះ**

**១. អ្នកដាក់ពាក្យបណ្តឹង**

មានតែសហព័ទ្ធទាំងពីរនាក់ទេដែលអាចដាក់ពាក្យបណ្តឹងលែងលះបាន។ សហព័ទ្ធជាប្តី ឬ ប្រពន្ធដែលជាអ្នកដាក់ពាក្យបណ្តឹងត្រូវបានហៅថា "**ដើមចោទ**" និងសហព័ទ្ធម្ខាងទៀតដែលត្រូវគេប្តឹងត្រូវបានហៅថា "**ចុងចម្លើយ**"។

របៀបដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងមានដូចជា៖

-ពាក្យបណ្តឹងត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ។

-នៅក្នុងលិខិតនៃពាក្យបណ្តឹង ដើមចោទត្រូវសរសេរចំណុចមួយចំនួនដូចជា៖

+ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

+ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។

---

[109] សាស្ត្រាចារ្យ ឥន ឿន, ២០១៣. នីតិគ្រួសារ និងអាពាហ៍ពិពាហ៍

[110] សាស្ត្រាចារ្យ ឥន ឿន, ២០១៣. នីតិគ្រួសារ និងអាពាហ៍ពិពាហ៍

-នៅក្នុងពាក្យបណ្តឹង ដើមចោទគប្បីសរសេរបញ្ជាក់ឲ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូល ហេតុនៃការទាមទារ និងភស្តុតាង[111]។

### ២. កន្លែងដាក់ពាក្យបណ្តឹង

សហព័ទ្ធទាំងសងខាងដែលមានបំណងចង់លែងលះអាចដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាឃុំសង្កាត់ខាងលំនៅដ្ឋានរបស់ភាគីចុងចម្លើយ ឬ អាចដាក់ផ្ទាល់ទៅកាន់សាលាដំបូងនៃលំនៅដ្ឋានចុងចម្លើយតែម្តងក៏បាន។

បណ្តឹងលែងលះគ្នា និងបណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃបុត្តភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខ របស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅដ្ឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬ លំនៅដ្ឋាននាពេលដែលភាគីនោះទទួលមរណភាព[112]។

### ៣. ស្ថាប័នមានសមត្ថកិច្ច

#### ៣.១. ក្រុមប្រឹក្សាឃុំ-សង្កាត់

ប្រសិនបើភាគីបានដាក់ពាក្យបណ្តឹងលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីដែលទទួលបន្ទុកត្រូវសាកល្បងធ្វើការផ្សះផ្សាក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹង។ ប្រសិនបើក្នុងរយៈពេល១៥ថ្ងៃ មេឃុំ ឬ ចៅសង្កាត់អាចធ្វើការផ្សះផ្សាឲ្យភាគីទាំងពីរត្រូវរ៉ូវគ្នា និងព្រមបន្តការរួមរស់ជាមួយគ្នា ពាក្យបណ្តឹងរបស់ភាគីដើមបណ្តឹងដែលបានដាក់នោះមិនចាំបាច់បញ្ជូនទៅតុលាការឡើយ ពីព្រោះបញ្ហានេះត្រូវបានដោះស្រាយចប់សព្វគ្រប់នៅក្រុមប្រឹក្សាឃុំ-សង្កាត់។ ប៉ុន្តែ បើក្នុងករណីមានការខិតខំប្រឹងប្រែងផ្សះផ្សាជាច្រើនលើកពីមេឃុំ ឬ ចៅសង្កាត់នៅតែមិនបានសម្រេចក្នុងរយៈពេល១៥ថ្ងៃ មេឃុំ ឬ ចៅសង្កាត់នៅត្រូវបញ្ជូនពាក្យបណ្តឹងទៅតុលាការជាបន្ទាន់ ព្រោះក្រុមប្រឹក្សាឃុំ-សង្កាត់ពុំមានអំណាចនៅក្នុងការសម្រេចឲ្យមានការលែងលះ ឬ សម្រេចអំពីសោហ៊ុយចិញ្ចឹមបីបាច់កូន ឬ អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ ឬ ការបែងចែកទ្រព្យសម្បត្តិ តាមពាក្យសុំរបស់ភាគីឡើយ[113]។

---

[111] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៧៥

[112] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០

[113] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨២

### ៣.២. តុលាការ

ប្រសិនបើការផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បរាជ័យ និងក្រោយពេលដែលតុលាការបានទទួលពាក្យបណ្តឹង ទោះបីជាភាគីជាមានការទាមទារយ៉ាងខ្លាំងចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន។ ក្នុងករណីដែលការផ្សះផ្សាពុំអាចសម្រេចបានទេនោះ តុលាការត្រូវយកបណ្តឹងលែងលះគ្នានោះ មកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម[114]។ ជាទូទៅការផ្សះផ្សាត្រូវបានធ្វើឡើង៣ដង ដោយគម្លាតនៃការផ្សះផ្សានីមួយៗមានរយៈពេល១ខែ។

#### ៣.២.១. ការពិនិត្យពាក្យបណ្តឹង

បន្ទាប់ពីតុលាការបានសាកល្បងធ្វើការផ្សះផ្សារយៈពេល៣ដងពុំទទួលបានសះជា តុលាការនឹងធ្វើការពិនិត្យទៅលើពាក្យបណ្តឹង។ ក្នុងករណីដែលពាក្យបណ្តឹងនោះមានចំណុចខ្វះខាតដូចជាចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ឬ ដើមចោទពុំបានបង់ពន្ធដាក់ពាក្យសុំ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឲ្យកែតម្រូវចំណុចខ្វះចំពោះពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ។ ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការត្រូវលើកពាក្យបណ្តឹងចោល ដោយដីកាសម្រេច[115]។

#### ៣.២.២. ការបញ្ជូនពាក្យបណ្តឹង

ក្រោយពីបានពិនិត្យពាក្យបណ្តឹងចប់សព្វគ្រប់ ហើយពាក្យបណ្តឹងនោះត្រឹមត្រូវតាមច្បាប់ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយជាចាំបាច់[116]។ ការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ គឺ ដើម្បីឲ្យចុងចម្លើយបានដឹងពីកម្មវត្ថុនៃបណ្តឹង និងទុកពេលឲ្យចុងចម្លើយធ្វើការឆ្លើយតប ឬរៀបចំមធ្យោបាយការពារខ្លួន។ នៅក្នុងករណីដែលរកទីសំណាក់របស់ចុងចម្លើយមិនឃើញដើមចោទអាចដាក់ពាក្យសុំទៅតុលាការ ដើម្បីទទួលការអនុញ្ញាតធ្វើការបញ្ជូនពាក្យបណ្តឹងតាមរយៈការផ្សាយជាសាធារណៈ[117]។ បណ្តឹងអាចចាត់ការបាន លុះត្រាតែពាក្យបណ្តឹងនោះបានបញ្ជូនដល់ចុងចម្លើយ។

#### ៣.២.៣. ការកំណត់កាលបរិច្ឆេទសម្រាប់ការទាញហេតុផលលើកដំបូង

នៅពេលដែលពាក្យបណ្តឹងបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងរយៈពេល៣០ថ្ងៃ និងកោះហៅគូភាគីដើម្បីចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[118]។ ក្នុងករណីដែលដើមបណ្តឹងមិនបានបង់ប្រាក់ចាំបាច់សម្រាប់កោះហៅ

---

[114] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨៥

[115] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៧៨

[116] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៧៩

[117] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា២៥៥

[118] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៨០

ភាគីចូលមកនៅកាលបរិច្ឆេទដែលបានកំណត់ តុលាការអាចលើកចោលបណ្តឹងដោយដីកាសម្រេចបាន ប្រសិនបើគ្មានការតវ៉ាពីចុងចម្លើយ[119]។

### ៣.២.៤. ឯកសារត្រៀម

នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឲ្យភាគីដាក់ឯកសារត្រៀមបាន។

នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និងសេចក្តីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត។

នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និងអង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង[120]។

តុលាការអាចកំណត់អំឡុងពេលដែលត្រូវដាក់ឯកសារត្រៀមលើកដំបូងរបស់ចុងចម្លើយ ឬ ឯកសារត្រៀមដែលមានសរសេរអំពីការអះអាងចំពោះចំណុចជាក់លាក់ណាមួយ ឬ ត្រូវធ្វើការស្នើសុំឲ្យពិនិត្យភស្តុតាងដែលទាក់ទងនឹងចំណុចជាក់លាក់ណាមួយ[121]។

### ៣.២.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់[122]។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនូវកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការបាន[123]។

---

119 ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៨២

120 ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០១

121 ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០២

122 ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៣

123 ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៥

នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចចេញដីកាសម្រេច ទាក់ទងនឹងការស្នើសុំឲ្យពិនិត្យភស្តុតាង ឬ ដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបាន ក្រៅពី កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងអាចពិនិត្យភស្តុតាងជាឯកសារ ដោយមាន កម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង។

ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីមិនអាចដាក់មធ្យោបាយ តទល់ ឬ ការពារខ្លួនថ្មីបានទៀតទេ។ ចំពោះករណីដែលមធ្យោបាយនោះ ទាក់ទងនឹងចំណុចដែល តុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬ ករណីដែលការដាក់មធ្យោបាយថ្មីនោះ មិនធ្វើ ឲ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ឬ ករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិន អាចដាក់មធ្យោបាយនោះ មុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុស ធ្ងន់ធ្ងរឡើយ ភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនបាន[124]។

តុលាការត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅ គ្រប់កាលបរិច្ឆេទនីមួយៗ[125]។

### ៣.២.៦. ការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវ កំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូល រួម[126]។

ដើម្បីចេញសាលក្រមទៅលើបណ្តឹងលៃងលះ តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញ ហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែ ចំពោះរឿងក្តី ឬ ចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនត្រូវធ្វើ។ ក្នុងករណីដែល មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចធ្វើការសាកសួរភាគីបាន[127]។

ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាច មានវត្តមានបាន។ ហើយការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅសវនាការជាសាធារណៈ។ ចំពោះករណីដែលភាពជាសាធារណៈនេះបណ្តាលឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬ ករណីដែល មានបញ្ញត្តិពិសេសក្នុងច្បាប់ ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនឹងមិនត្រូវបានធ្វើ ឡើងនោះទេ[128]។

[124] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៨

[125] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៩

[126] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១១៣

[127] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១១៤

[128] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១១៥

នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់នេះដែរ ភាគីទាំងសងខាងត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីចង្អុលបង្ហាញឲ្យបានច្បាស់នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាង ដែលនឹងត្រូវធ្វើនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ ហើយនៅពេលដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ភាគីទាំងសងខាងអាចអះអាងអំពីអង្គហេតុ និងអាចដាក់ភស្តុតាងមកទៀតបាន[129]។

ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយ បើយល់ឃើញថា ត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថ្មីម្តងទៀតបានដោយដីកាសម្រេច។ តុលាការអាចអនុញ្ញាតឲ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយបាន មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់[130]។

### ៣.២.៧. ការចេញសាលក្រម

សាលក្រម គឺជាការសម្រេចសេចក្តីដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់[131]។

#### ៣.២.៧.១. អត្ថន័យនៃសាលក្រម

តុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ។ តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានស្នើសុំឡើយ[132]។ ក្នុងន័យនេះដែរ មិនមែនមានន័យថា តុលាការត្រូវតែសម្រេចទៅតាមការស្នើសុំទាំងអស់របស់ភាគីនោះទេ តុលាការអាចសម្រេចតាមឆន្ទានុសិទ្ធិរបស់ខ្លួនបាន ប្រសិនបើយល់ឃើញថា ការសម្រេចនោះផ្តល់ផលប្រយោជន៍ដល់ភាគី។

នៅក្នុងសាលក្រមស្តីពីការលែងលះនេះផងដែរ តុលាការអាចធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ហើយបើមានពាក្យសុំរបស់ភាគី តុលាការអាចសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងទៅនឹងការបីបាច់ថែរក្សាកូន ឬ ការចាត់ចែងទាក់ទងទៅនឹងការបែងចែកទ្រព្យសម្បត្តិ។ មិនតែប៉ុណ្ណោះ តុលាការអាចសម្រេចនូវបញ្ហាមួយចំនួនផ្សេងទៀតដូចជា បញ្ហាអាហារកិច្ច បញ្ហាបីបាច់ថែរក្សាកូន បញ្ហាផ្គត់ផ្គង់កូន និងការបង្គាប់ឲ្យភាគីប្រគល់កូន ឬ ការផ្តល់តាវកាលិកផ្សេងៗទៀត។ ប៉ុន្តែចំពោះបញ្ហាកូន តុលាការក៏ត្រូវថ្លឹងថ្លែងយោបល់របស់កូន ដោយគិតពិចារណាអំពីអាយុរបស់កូន និងភាពចាស់ទុំរបស់កូន[133]។

---

[129] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១១៦

[130] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១១៦

[131] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៧៩

[132] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៨២

[133] សាស្ត្រាចារ្យ ឥន យឿន, ២០១៣. នីតិគ្រួសារ និងអាពាហ៍ពិពាហ៍

តុលាការត្រូវសម្រេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ[134]។

### ៣.២.៧.២. ការចូលជាស្ថាពររបស់សាលក្រម

សាលក្រមនឹងមានអានុភាពដោយការប្រកាស។ ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល១ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះករណីដែលរឿងក្តីនោះមានភាពស្មុគស្មាញខ្លាំង ឬ មានកាលៈទេសៈ រយៈពេលនៃការប្រកាសសាលក្រមនេះអាចពន្យារបាន[135]។

លិខិតសាលក្រមត្រូវបញ្ជូនទៅឲ្យភាគី ក្នុងអំឡុងពេល២សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ[136]។

សាលក្រមមិនអាចចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលនៃបណ្តឹងទាស់ (២សប្តាហ៍គិតចាប់ពីថ្ងៃដែលទទួលបានការបញ្ជូនសាលក្រមកំបាំងមុខ) និងអំឡុងពេលប្តឹងឧទ្ធរណ៍ (១ខែគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម[137])។

### ៣.២.៧.៣. អានុភាពនៃសាលក្រមស្ថាពរ

សាលក្រមស្ថាពរមានអានុភាពចំពោះបុគ្គលដែលបានកំណត់ដូចខាងក្រោម៖

-ភាគី

-តតិយជន ក្នុងករណីដែលភាគីធ្វើជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងជំនួសតតិយជននោះ

-បុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ពីអ្នកដែលបានកំណត់ក្នុងចំណុចទាំង២ខាងលើ ក្រោយពីបណ្តឹងត្រូវបានចាត់ការ

-បុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់ផលប្រយោជន៍របស់បុគ្គលដែលបានកំណត់ក្នុងចំណុចទាំង៣ខាងលើ[138]។

## ៤. ការចាត់ចែងរក្សាការពារ

វិធានការរក្សាការពារ គឺមានបំណងដោះស្រាយបញ្ហាខ្លះរវាងសហាព័ទ្ធទាំងពីរក្នុងពេលដែលពួកគេរង់ចាំសាលក្រមស្តីពីការលែងលះចូលជាស្ថាពរ។

---

[134] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៨២
[135] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៨៧
[136] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៩០
[137] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៩៣, មាត្រា២០៤ និងមាត្រា២៦៤
[138] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៩៨

ក្រោយពេលដែលទទួលពាក្យបណ្ដឹងលែងលះគ្នា ក្នុងករណីចាំបាច់ តុលាការអាចចេញដីកាសម្រេចបង្គាប់ឲ្យធ្វើការចាត់ចែងរក្សាការពារចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ[139]។

## ផ្នែកទី២៖ អានុភាពនៃការលែងលះ

### កថាខណ្ឌ១៖ ការរំលាយចំណងអាពាហ៍ពិពាហ៍

ក្រោយពីថ្ងៃប្រកាសសាលក្រមស្ដីពីការលែងលះ ហើយសាលក្រមនោះចូលជាស្ថាពរ ចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធទាំងពីរត្រូវបានរំលាយ។ កាតព្វកិច្ច និងករណីយកិច្ចរបស់សហព័ទ្ធទាំងពីរក៏ត្រូវបានបញ្ចប់ផងដែរ។ សហព័ទ្ធទាំងពីរអាចជ្រើសរើសគូស្រករថ្មីក្រោយពេលសាលក្រមចូលជាស្ថាពរ។ ប៉ុន្តែចំពោះភាគីនារី ការរៀបអាពាហ៍ពិពាហ៍ថ្មីនឹងមិនត្រូវបានអនុញ្ញាតឡើយក្នុងអំឡុងពេល១២០ថ្ងៃ គិតចាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ។ ក្នុងករណីនេះផងដែរ ការហាមឃាត់នេះមិនអាចត្រូវបានយកអនុវត្តឡើយ កាលបើភាគីនារីមានផ្ទៃពោះមុនពេលអាពាហ៍ពិពាហ៍នេះត្រូវបានរំលាយ ឬ មានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត[140]។ ចំពោះភាគីបុរសវិញ ការរៀប អាពាហ៍ពិពាហ៍ថ្មីមិនត្រូវបានហាមឃាត់ឡើយ ក្រោយពេលដែលសាលក្រមចូលជាស្ថាពរ។

### កថាខណ្ឌ២៖ ការបែងចែកទ្រព្យសម្បត្តិ

ក្រោយពេលលែងលះ សហព័ទ្ធទាំងពីរតែងតែទាមទារនូវចំណែកទ្រព្យសម្បត្តិរៀងៗខ្លួន ព្រមទាំងហ៊ានអះអាងនៅចំពោះមុខតុលាការថា ទ្រព្យសម្បត្តិទាំងអស់ គឺជាញើសឈាមដែលខ្លួនខំរកក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ដោយផ្អែកលើគំនិត និងទំនៀមទម្លាប់ប្រពៃណីខ្មែរ ស្ដ្រីដែលជាភរិយាក្រោយពេលរៀបការប្រកាន់យកតួនាទីតែមួយគត់ នោះគឺការងារផ្ទះ។ ដោយកត្តានេះហើយដែលស្ត្រីមួយចំនួនរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្រោយពេលលែងលះ ដោយខ្លួនពុំបានទទួលនូវទ្រព្យសម្បត្តិអ្វីឡើយ ព្រោះខ្លួនពុំបានប្រកបមុខរបរ ឬ រកស៊ីអ្វីទាំងអស់។ ប៉ុន្តែទោះជាយ៉ាងណាសេចក្ដីសម្រេចក្នុងករណីខាងលើ គឺកើតឡើងតែក្នុងអតីតកាលតែប៉ុណ្ណោះ។ ក្នុងពេលបច្ចុប្បន្ន ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងយ៉ាងច្បាស់លាស់អំពីការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងសងខាង ព្រមទាំងបានកំណត់នូវការប្រកាន់យកប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងការប្រកាន់យកប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់ ដើម្បីបង្កលក្ខណៈងាយស្រួលនៅពេលលែងលះ។

---

[139] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨៣

[140] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៥០

### ១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺសំដៅដល់ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ប៉ុន្តែកិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកិច្ច និងភាគបម្រុងបានឡើយ[141]។ ការធ្វើកិច្ចសន្យានេះ គឺជាការព្រមព្រៀងរវាងសហព័ទ្ធទាំងពីរក្នុងការចាត់ចែងទ្រព្យសម្បត្តិតាមការកំណត់របស់ពួកគេនៅក្នុងកិច្ចសន្យា។ មួយវិញទៀត កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវធ្វើការចុះបញ្ជីផងដែរ[142]។ ការកំណត់យកប្រព័ន្ធទ្រព្យសម្បត្តិប្រភេទនេះ នៅពេលមានការលែងលះកើតឡើង សហព័ទ្ធទាំងសងខាង អាចយកនូវទ្រព្យសម្បត្តិរបស់ខ្លួនដូចដែលមានចែងក្នុងកិច្ចសន្យា។ វាហាក់ដូចជា ពួកគេទាំងពីរបានព្រមព្រៀងគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិ។ ប៉ុន្តែក្នុងករណីដែលសហព័ទ្ធទាំងពីរមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ពួកគេត្រូវយកតាមប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់។

### ២. ប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់

ក្នុងករណីដែលសហព័ទ្ធទាំងពីរមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ពួកគេត្រូវយកតាមប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់[143]។ ប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់មាន២ប្រភេទគឺ ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។

#### ២.១. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬ ទ្រព្យដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ ទ្រព្យដែលជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានរៀបរាប់ខាងលើ[144]។ ក្នុងករណីមានការលែងលះគ្នាដោយគ្មានការព្រមព្រៀងលើការបែងចែកទ្រព្យសម្បត្តិ សហព័ទ្ធនីមួយៗត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន[145]។

#### ២.២. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍[146]។ វាជាទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងពីរបានខិតខំស្វែងរកបាន

---

[141] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៩

[142] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧០

[143] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៩

[144] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧២

[145] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨០

[146] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៣

ក្រោយពេលដែលពួកគេបានក្លាយជាប្ដីប្រពន្ធស្របច្បាប់។ ក្នុងករណីមានការលែងលះកើតឡើងប្រសិនបើគ្មានការព្រមព្រៀងលើការបែងចែកទ្រព្យសម្បត្តិដោយសហព័ទ្ធទាំងសងខាង សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ភាគ២ នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែបើមានករណីពិសេស និងការទាមទាររបស់ប្ដីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមាន ចំណងអាពាហ៍ពិពាហ៍ អាយុស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងារ របស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍[147]។

**កថាខណ្ឌ៣៖ ការប្រគល់អំណាចមេបា**

**១. តាមការព្រមព្រៀង**

នៅពេលឪពុកម្ដាយលែងលះគ្នា ការកំណត់យកឪពុក ឬ ម្ដាយណាម្ខាងជាអ្នកមានអំណាចមេបា គឺត្រូវធ្វើឡើងតាមការពិភាក្សារបស់ឪពុកម្ដាយ។ ក្នុងករណីដែលកូននោះនៅក្នុងផ្ទៃនៅឡើយម្ដាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលកើតមកនោះ។ ប៉ុន្តែការកំណត់យកឪពុក ឬ ម្ដាយជាអ្នកមានអំណាចមេបាក្រោយពេលដែលកូននោះបានកើត គឺអាចធ្វើឡើងតាមការពិភាក្សារបស់ឪពុកម្ដាយបាន[148]។

**២. មិនតាមការព្រមព្រៀង**

កាលបើសហព័ទ្ធទាំងពីរមិនបានសម្រេច ឬ ពុំអាចពិភាក្សាបានទេ តុលាការជាអ្នកមានសិទ្ធិសម្រេចប្រគល់អំណាចមេបាទៅឲ្យភាគីណាម្ខាង ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ[149]។ តុលាការនឹងពិនិត្យទៅលើស្ថានភាពជីវភាពរបស់សហព័ទ្ធទាំងសងខាងមុនធ្វើការសម្រេចអ្នកមានអំណាចមេបា ព្រោះដើម្បីធានាភាពស្រណុកសុខស្រួលរបស់ សុខុមាលភាព និងការអប់រំដល់កុមារ។ ម្យ៉ាងវិញទៀត តុលាការអាចផ្ដល់សិទ្ធិដល់កូនក្នុងការជ្រើសរើសអ្នកមានអំណាចមេបាតាមចិត្តរបស់ខ្លួន ប្រសិនបើកូននោះចេះនិយាយ។ ក្នុងករណីដែលកូននោះមានអាយុតិចពេក មិនទាន់ចេះនិយាយ និងស្ថិតក្នុងដំណាក់កាលបៅដោះម្ដាយនៅឡើយ ជាគោលការណ៍ ប្រសិនបើតុលាការពិនិត្យឃើញថា ភាគីជាម្ដាយមានលទ្ធភាពអាចផ្គត់ផ្គង់ និងចិញ្ចឹមបីបាច់ថែរក្សាកូននោះបានល្អ តុលាការនឹងសម្រេចឲ្យភាគីម្ដាយជាអ្នកមានអំណាចមេបា។ ប៉ុន្តែនៅពេលដែលកូននោះចេះនិយាយ ភាគីជាឪពុកអាចប្ដឹងទាមទារអំណាចមេបាលើកូននោះបាន ដោយតុលាការនឹងសាកសួរកូននោះថា តើចង់ទៅរស់នៅជាមួយឪពុក ឬ ជាមួយម្ដាយ? តុលាការនឹងសម្រេចអ្នកមានអំណាចមេបាតាមការសម្រេចរបស់កូននោះ។

---

147 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨០

148 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៧

149 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៧

Ministère des Affaires Etrangères et Européennes
Service de la valise diplomatique
13 rue Louveau
92438 Chatillon Cedex

14 AVENUE MAURICE THOREZ
94200 IVRY-SUR-SEINE

Madame, Monsieur,

Je vous prie de bien vouloir trouver ci-joint un certificat de capacité à mariage qui vous permettra de contracter mariage devant les autorités locales.

J'attire votre attention sur l'avertissement contenu dans ce certificat notamment quant à la présence obligatoire du ou des conjoints français lors de la célébration du mariage devant les autorités locales.

Si, une fois le mariage célébré, vous souhaitez faire enregistrer votre acte de mariage par les autorités françaises en vue notamment d'obtenir un livret de famille, vous voudrez bien me faire parvenir les documents suivants :
- une demande de transcription signée par le ou les conjoints français (voir imprimé ci-joint),
- les pièces visées dans la liste ci-jointe.

Veuillez agréer, Madame, Monsieur, l'assurance de ma considération distinguée.

Daniel MARCERRE
Consul Adjoint
Chef de Chancellerie

សាលាដំបូងរាជធានីភ្នំពេញ
ចូល | សំណុំរឿងលេខ 829
ថ្ងៃទី 28 ខែ 4 ឆ្នាំ 2015
ម៉ោង.........នាទី.........នាទី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្ដឹង

**ដើមបណ្ដឹង:** ឈ្មោះ «ក» ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាស័យដ្ឋាន ផ្ទះលេខ ៦១សេ ផ្លូវលេខ ៣៥៥ ក្រុមទី៥ ភូមិដើមអំពិល មណ្ឌល១១ សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ចុងចម្លើយ:** ឈ្មោះ «ខ» ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាស័យដ្ឋាន ផ្ទះលេខ ៦១សេ ផ្លូវលេខ ៣៥៥ ក្រុមទី៥ ភូមិដើមអំពិល មណ្ឌល១១ សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

## សូមគោរពជូន

## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ:** ប្ដឹងសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម:

១- ប្ដឹងសុំឈប់រស់នៅផ្ដាច់នីតិសង្វាស់ពីប្ដីឈ្មោះ «ខ» អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាស័យដ្ឋានផ្ទះលេខ ៦១សេ ផ្លូវលេខ ៣៥៥ ក្រុមទី៥ ភូមិដើមអំពិល មណ្ឌល១១ សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

២- សុំសិទ្ធិអំណាចមេបាលើកូនចំនួន៣នាក់ ១-ឈ្មោះ «គ» ភេទស្រី កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ ២-ឈ្មោះ «ឃ» ភេទស្រី កើតនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៥ ៣- ឈ្មោះ «ង» ភេទស្រី កើតនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩ ។

៣- សុំប្រគល់រថយន្តម៉ាតលុចស៊ីស សេរី៤៧០ ឱ្យទៅចុងចម្លើយ ជាកម្មសិទ្ធិ ។

៤- សុំប្រគល់ដីទំហំ២០អាស្មើនឹង ៣.២០០០ (បីហិចតាពីរពាន់ម៉ែត្រ)ដែលមានទីតាំងស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីលេខ០៨៦/០៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ។និងដីទំហំ២៩អាស្មើនឹង ៤.៦៤០០ (បួនហិចតាប្រាំមួយពាន់បួនរយម៉ែត្រ) មានទីតាំងស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីលេខ០៨៥/០៦ ភព្រ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ឱ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ។

៥- សុំប្រគល់ដីទំហំ២៤អាស្មើនឹង៣.៨៤០០ (បីហិចតាប្រាំពាន់បួនរយម៉ែត្រ) ដែលមានទីតាំង ស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីចុះថ្ងៃទី២ ខែមករា ឆ្នាំ២០០៦ ឱ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ។

៦- សុំប្រគល់ដីទំហំ១៣ អាស្មើនឹង ២.៨០០ (ពីរហិចតាប្រាំបីរយម៉ែត្រ)ដែលទីតាំងនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង មានលិខិតបញ្ជាក់លក់ដីចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦។ ដីដែលនៅក្នុងភូមិឃុំដូចបានរៀបរាប់ខាងលើ សរុប

ចំនួន១៣.៧៦០០(ដប់បីហិចតាប្រាំពីរពាន់ ប្រាំមួយរយម៉ែត្រ) ឱ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ។

៧- ដើមចោទសុំសិទ្ធិគ្រប់គ្រងលើដី-ផ្ទះដែលកំពុងសាងសង់មានទីលំនៅស្ថិតនៅភូមិទួលរការ(៣) សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានទំហំ២៨៧,៧០ ម៉ែត្រក្រឡា ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី លេខ៣៨៥៧បជ.មជ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ជាម្ចាស់កម្មសិទ្ធិ ។

៨- បំណុលធនាគារចំនួន៣០០០០(បីម៉ឺនដុល្លាអាមេរិក) ដើមចោទជាអ្នកទទួលសងតែម្នាក់ឯង។

៩- ដីចំការទំហំ ១៣៨៨៨,១២៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀង ខេត្តកំពង់ឆ្នាំង ដែលមានកិច្ចសន្យាលក់អចលនវត្ថុលេខ ៣៣៥/០៨ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ -ដីទំហំបណ្តោយ៥១ម៉ែត្រ ទទឹង២៦ម៉ែត្រ មានទីលំនៅស្ថិតនៅភូមិស្វាយរៀង ឃុំស្វាយរៀងក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលមានកិច្ចសន្យាទិញ-លក់អចលនទ្រព្យលេខ ៤៩១/០៨ ឃ.ស្វរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ និងដីស្រែទំហំ១៨៥៤.៣៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ៦៧៨/១៥ ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៥ ។ ដីដែលបានជម្រាបជូន នៅខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង នាងខ្ញុំសូមប្រគល់ទុកឱ្យកូនទាំងបីនាក់ ។

<u>យោង:</u>
- សៀវភៅស្នាក់នៅលេខ ១៨០៧ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៥
- កិច្ចសន្យាសាម៉ីខ្លួនកូនប្រុស និងកូនស្រីចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ។
- កិច្ចសន្យាសាម៉ីខ្លួនកូនប្រុស និងកូនស្រី ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ ។
- កិច្ចសន្យាលក់អចលនវត្ថុលេខ ៣៣៥/០៨ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ ។
- ពាក្យសុំផ្ទេរកម្មសិទ្ធិលេខ០៨៥/០៦ ភព្រ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ។
- លិខិតបញ្ជាក់លក់ដី ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០០៦ ។
- លិខិតបញ្ជាក់ដីលេខ០៨៦/០៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ។
- លិខិតបញ្ជាក់លក់ដីលេខ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦ ។
- កិច្ចសន្យាទិញ-លក់អចលនទ្រព្យលេខ ៤៩១/០៨ ឃ.ស្វ.រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ ។
- លិខិតកាន់កាប់ដីលេខ៦៧៨/១៥ ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៥ ។

**សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត**

តបតាមកម្មវត្ថុនិងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា: នៅអំឡុងឆ្នាំ២០០០ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ «ប» ក្រោយពីរៀបអាពាហ៍ពិពាហ៍រួច នាងខ្ញុំបានមានកូន ០៣នាក់ ១- ឈ្មោះ «គ» ភេទស្រី កើតនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០២ ២- ឈ្មោះ «យ» ភេទស្រី កើតនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៥។

៣-ឈ្មោះ [illegible] ភេទស្រី កើតនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩។ នៅក្នុងពេលដែលរួមរស់ជាប្តីប្រពន្ធ នាងខ្ញុំបានរកមុខរបរទាំងបានទ្រព្យសម្បត្តិ រួមមួយចំនួន ដូចមានឯកសារបញ្ជាក់ជូនខាងលើស្រាប់។ ហើយឥឡូវនេះប្តីរបស់នាងខ្ញុំតែងតែយកទ្រព្យសម្បត្តិចាយហាយមានរថយន្តម៉ាក លុចស៊ុស៤៧០ បានយកទៅលក់មិនគិតពីប្រពន្ធកូន មិនសូវចូលផ្ទះ ដើរចាក់ៗពីផ្ទះ ហើយប្រាក់ដែលបានមកពីការជួលដីទៅឲ្យគេស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបងក្នុងមួយឆ្នាំ៥០០០$ (ប្រាំពាន់ដុល្លាអាមេរិក) ក៏ប្តីនាងខ្ញុំមិនដែលយកចូលផ្ទះដែរ ជាពិសេសនៅពេលចូលផ្ទះម្តងៗ ប្តីនាងខ្ញុំតែងតែរករឿងប្រើអំពើហិង្សាមកលើនាងខ្ញុំ និងកូនៗ ដែលជាហេតុធ្វើឲ្យនាងខ្ញុំអស់មនោសញ្ចេតនាជាប្តី ប្រពន្ធតទៅទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម លោកប្រធាន មេត្តាសម្រេចចេញសាលក្រមឲ្យនាងខ្ញុំដោយក្តីអនុគ្រោះ។

សូម លោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៧ ខែ៤ ឆ្នាំ២០១៥

ស្នាមមេដៃស្តាំ

[illegible]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

ចូល

**CVLF**

**ការិយាល័យមេធាវី ចំន្ទ វិចិត្រ**

**CHANN VICHET LAW FIRM**

## លិខិតតំណាងដោយអាណត្តិ

ខ្ញុំបាទមេធាវី ស៊ិន ផល្លា សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

អត្តលេខៈ ៧៨៧ ។

**សូមគោរពចូលមក**

## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

សូមមេត្តាជ្រាប ។

**កម្មវត្ថុៈ** ស្តីពីមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៨២៩ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោងៈ**
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ « [illegible] » ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ។

តាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាប ថាៈ កូនក្តីឈ្មោះ « [illegible] » បានប្រគល់សិទ្ធិអោយខ្ញុំបាទ ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចដែលបានរៀបរាប់នៅក្នុងកម្មវត្ថុខាងលើ ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកប្រធាន** មេត្តាពិនិត្យ និង ទទួលស្គាល់តាម នីតិវិធីដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**មេធាវី. ស៊ិន.ផល្លា**

ផ្ទះលេខ ២៦ AEo ផ្លូវ ២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ :...012 55 7894......

# 26AEo, St.213 Sangkat Vealvong, Khan 7Makara, Phnom Penh Tel :..........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំអាណត្តិទាយកឈ្មោះ [illegible] ភេទ [illegible] អាយុ..........ឆ្នាំ ជនជាតិ [illegible]
សញ្ជាតិ [illegible] មុខរបរ.................... ទីលំនៅផ្ទះលេខ.............. ផ្លូវលេខ..............
ភូមិ/មណ្ឌល [illegible] ក្រុម.............. ឃុំ/សង្កាត់ [illegible] ក្រុង/ស្រុក/ខណ្ឌ
[illegible] រាជធានី/ខេត្ត [illegible] ។

## សូមប្រគល់សិទ្ធិជូន

លោកមេធាវី [illegible] អត្តលេខ 787 អាសយដ្ឋានផ្ទះលេខ [illegible]
ផ្លូវលេខ [illegible] ភូមិ.............. សង្កាត់ [illegible] ខណ្ឌ [illegible] រាជធានីភ្នំពេញ ។

ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំ និង ធ្វើការអាណត្តិនូវកិច្ចការដូចខាងក្រោមៈ

- ☑ ធ្វើសកម្មភាពតំណាង ☑ ដាក់ពាក្យបណ្តឹង ឬ បណ្តឹងតប ☑ ផ្សះផ្សា
- ☑ លះបង់ការទាមទារ ☑ ទទួលស្គាល់ការទាមទារ ☑ ដកពាក្យបណ្តឹង
- ☑ ដកខ្លួនចេញពីពាក្យបណ្តឹង ☑ ដាក់ពាក្យបណ្តឹងទាស់ ☑ ដាក់បណ្តឹងឧទ្ធរណ៍
- ☑ ដាក់ពាក្យបណ្តឹងជំទាស់ ☑ ដាក់ពាក្យបណ្តឹងសាទុក្ខ

ក្នុងសំណុំរឿង [illegible] លេខ 829 ចុះថ្ងៃទី 28 ខែ [illegible] ឆ្នាំ 2015
របស់ [illegible] ។

បញ្ជាក់ៈ សោហ៊ុយចំណាយលើការបង់កន្លៃផ្សេងៗ នៅក្នុងបណ្តឹងនេះជាបន្ទុករបស់ខ្ញុំ(អាណត្តិទាយក) ។ ក្នុងករណីមិនបានគោរពនូវកាតព្វកិច្ចនេះ ខ្ញុំ(អាណត្តិទាយក)សុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់ ។

លោកមេធាវីតំណាងដោយអាណត្តិមានសិទ្ធិអនុវត្តកិច្ចការអាណត្តិតាមច្បាប់ ដែលអាណត្តិទាយកបានប្រគល់ជូនដូចខាងលើ ចាប់ពីថ្ងៃផ្តិតមេដៃ ឬ ចុះហត្ថលេខានេះតទៅ ។

[illegible] ថ្ងៃទី 28 ខែ 3 [illegible] ឆ្នាំ 2015

បានឃើញ និង យល់ព្រម
ធ្វើជាមេធាវីតំណាងដោយអាណត្តិទាយកឲ្យឈ្មោះ
[illegible]
[illegible] ថ្ងៃទី [illegible] ឆ្នាំ 2015

ឃ ម៉ៅ

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

☑.យល់ព្រម
☒.មិនយល់ព្រម

មេធាវី.ស៊ិន_ផល្លា

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំពិនិត្យ និងថតចម្លងឯកសារ

ខ្ញុំបាទមេធាវី ស៊ិន ផល្លា សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

អត្តលេខៈ៧៨៧។

## សូមគោរពចូលមក

## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

សូមមេត្តាជ្រាប ។

**កម្មវត្ថុ៖** សុំពិនិត្យ និងថតចម្លងឯកសារ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៨២៩ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

តាមកម្មវត្ថុខាងលើខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថាៈ ខ្ញុំបាទត្រូវបានកូនក្តីប្រគល់សិទ្ធិ ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិ នៅក្នុងសំណុំរឿងរដ្ឋប្បវេណី ៨២៩ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥។ ប៉ុន្តែខ្ញុំបាទនៅពុំទាន់បាន ពិនិត្យ និងសុំថតចម្លងឯកសារ ដើម្បីការពារផលប្រយោជន៍កូនក្តីតាមផ្លូវច្បាប់នៅឡើយ។

អាស្រ័យហេតុនេះសូម **លោកប្រធាន** មេត្តាពិនិត្យ និងអនុញ្ញាតដោយក្តី អនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**មេធាវី.ស៊ិន-ផល្លា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខ ៨២៩

ចុះថ្ងៃទី ២៨-៤-២០១៥

# ដីកាអញ្ជើញ

*អនុប្រធាន ទេព.ហ៊ត់ និងជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។*

អញ្ជើញឈ្មោះ « ក » ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៦១C ផ្លូវ៣៥៥ក្រុមទី៥ភូមិដើមអំពិលមណ្ឌល១១ សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញជាចុងដើមបណ្ដឹង អញ្ជើញទៅកាន់ *សាលាដំបូងរាជធានីភ្នំពេញ* ដូចកាលកំណត់ខាងក្រោម

ថ្ងៃខែឆ្នាំត្រូវចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ៖ ដោយសារតុលាការមានការងារច្រើនដូច្នេះការចូលជួបចៅក្រមត្រូវតាមពេលវេលា ជៀសវាងរង់ចាំចៅក្រមយូរ និងខាតពេលវេលា។

លោកចៅក្រម ទេព.ហ៊ត់ អមដោយលោក មាស.ស្អាង និងជួយសម្រួលកិច្ចការជូនលោក ហើយរង់ចាំទទួលលោក លោកស្រី នៅការិយាល័យអគារ- ១ - ជាន់ទី៤ ថ្ងៃទី.ខែឧសភា ឆ្នាំ២០១៥ នៅវេលាម៉ោង ៨.៣០ នាទីព្រឹក

-គោលបំណងនៃការអញ្ជើញចូលរួម ដើម្បីចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។អង្គហេតុនេះទាក់ទងនឹងដើមបណ្ដឹងលោកស្រីប៉ែន.សុខនប្ដឹងសុំលែងលះពីលោក ឈ.សុខា

សូមលោក លោកស្រីអញ្ជើញទៅអោយទាន់ពេលវេលា និង ត្រូវយកលិខិតដែលមានប្រយោជន៍ក្នុងអង្គហេតុខាងលើមកជាមួយផង ប្រសិនបើមាន ដើម្បីតុលាការមានលទ្ធភាពពិនិត្យជូនតាមច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា២០១៥

ចៅក្រម

ទេព ហ៊ត់

យើង..........................................ជា........................................

បានប្រគល់ដីកានេះឱ្យឈ្មោះ............................ត្រូវជា.........................

នៅសព្វថ្ងៃផ្ទះលេខ.......ផ្លូវ..........ក្រុម.......ភូមិ...................................

ឃុំ/សង្កាត់.............ស្រុក/ខណ្ឌ..............ខេត្ត/រាជធានី .........................។

នៅថ្ងៃទី........ខែ..........ឆ្នាំ២០១៥ ផ្ទាល់រួចហើយ ដោយយើងបាន ទុកចុងដីកានេះមួយច្បាប់ឱ្យសាមីខ្លួនហើយប្រាប់ឱ្យសាមីខ្លួនប្រគល់ចុងដីកានេះ ដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលទៅដល់សាលាដំបូងរាជ ធានីភ្នំពេញ។

| | |
|---|---|
| អ្នកទទួលដីកា | អ្នកប្រគល់ដីកា |
| ហត្ថលេខា ឬ ផ្តិតមេដៃ | ហត្ថលេខា |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខ ៨២៩

ចុះថ្ងៃទី ២៨-៤-២០១៥

# ដីកាអញ្ជើញ

*អនុប្រធាន ទេព.ហ៊ិត់ និងជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។*

អញ្ជើញឈ្មោះ [illegible] ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៦១C ផ្លូវ៣៥៥ក្រុមទី៥ភូមិដើមអំពិលមណ្ឌល១១ សង្កាត់ច្បាអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញជាចុងដើមបណ្ដឹង អញ្ជើញទៅកាន់ *សាលាដំបូងរាជធានីភ្នំពេញ*ដូចកាលបរិច្ឆេទខាងក្រោម

<u>ថ្ងៃខែឆ្នាំត្រូវចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ៖</u> ដោយសារតុលាការមានការងារច្រើន ដូច្នេះការចូលជួបចៅក្រមត្រូវតាមពេលវេលា ជៀសវាងរង់ចាំចៅក្រមយូរ និងខាតពេលវេលា។

លោកចៅក្រម ទេព.ហ៊ិត់ អមដោយលោក មាស.ស្អាង និងជួយសម្រួលកិច្ចការជូនលោក ហើយរង់ចាំទទួលលោក លោកស្រី នៅការិយាល័យអក្សរ ១ ជាន់ទី៤ ថ្ងៃទី.ខែឧសភា ឆ្នាំ២០១៥ នៅវេលាម៉ោង ៨.៣០ នាទីព្រឹក

-<u>គោលបំណងនៃការអញ្ជើញចូលរួម</u> ដើម្បីចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ អង្គហេតុនេះទាក់ទងនឹងដើមបណ្ដឹងលោកស្រី ប៉ែន.សុខន ប្ដឹង សុំលែងលះពីលោក សយ.សុធា ។

សូមលោក លោកស្រីអញ្ជើញទៅអោយទាន់ពេលវេលា និង ត្រូវយកលិខិតដែលមានប្រយោជន៍ក្នុងអង្គហេតុខាងលើមកជាមួយផង ប្រសិនបើមាន ដើម្បីតុលាការមានលទ្ធភាពពិនិត្យជូនតាមច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា២០១៥

ចៅក្រម

ទេព ហ៊ិត់

យើង............................................ជា............................................
បានប្រគល់ដីកានេះឲ្យឈ្មោះ.............................ត្រូវជា.........................
នៅសព្វថ្ងៃផ្ទះលេខ.......ផ្លូវ...........ក្រុម.......ភូមិ..................................
ឃុំ/សង្កាត់.............ស្រុក/ខណ្ឌ..............ខេត្ត/រាជធានី ...........................។
នៅថ្ងៃទី........ខែ.........ឆ្នាំ២០១៥ ផ្ទាល់រួចហើយ ដោយយើងបាន ទុកចុងដីកានេះមួយឡប់ឲ្យសាមីខ្លួនហើយប្រាប់ឲ្យសាមីខ្លួនប្រគល់ចុងដីកានេះ ដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលទៅដល់សាលាដំបូងរាជធានីភ្នំពេញ។

| អ្នកទទួលដីកា | អ្នកប្រគល់ដីកា |
|---|---|
| ហត្ថលេខា ឬ ផ្ដិតមេដៃ | ហត្ថលេខា |

សាលាដំបូងរាជធានីភ្នំពេញ
៦៤១
៣០ មេសា ២០១៥
៤ ០០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសំរាប់**

**ការទាញហេតុផលនៅក្នុងនីតិវិធីទាញដោយផ្ទាល់មាត់**

ខ្ញុំបាទឈ្មោះ «ក» ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិផ្ទះលេខ៦១Cផ្លូវ៣៥៥ ក្រុម៥ ភូមិដើមអំពិលសង្កាត់ព្យាអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**ជូនចៅក្រមបន្ទប់ - ៩**
**ពិនិត្យ និងចាត់ការ**

**<u>សូមគោរពចូលមក</u>**

**លោកចៅក្រមទទួលបន្ទុករឿងក្តីសាលាដំបូងរាជធានីភ្នំពេញ**

<u>សូមទានជ្រាប។</u>

**កម្មវត្ថុ៖** ស្នើសុំជូនសេចក្តីថ្លែងការណ៍ និង សំអាងជាកសិណសាក្សី និងជាឯកសារដែលទាក់ទិនទៅនិងសំណុំរឿងរដ្ឋប្បវេណីលេខ៖ ៨២៩ចុះថ្ងៃទី២៨ ខែមេសាឆ្នាំ ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុខាងលើនេះ យើងខ្ញុំសូមជំរាបជូនលោកចៅក្រមជ្រាបថាមុននឹងថ្លែងអំពី អង្គហេតុ និងអង្គច្បាប់នៃសំណុំរឿងក្នុងនីតិវិធីទាញហេតុផលនេះ យើងខ្ញុំសូមថ្លែងនូវលទ្ធផលនៃនីតិវិធីត្រៀម ទាញហេតុផលកន្លងមកសិន ទើបថ្លែងអំពីអង្គហេតុ និងអង្គច្បាប់ក្នុងនីតិវិធីទាញហេតុផលជាចុងក្រោយ៖

លទ្ធផលនៃនីតិវិធីត្រៀមទាញហេតុផល៖

ការទាមទាររបស់ដើមចោទមានដូចជា៖

- ការសុំចេញសាលក្រម៖

១. ដើមបណ្តឹងឈ្មោះ «ក» ប្តឹងសុំលែងលះនៅផ្លូវចំនីតិសង្វាស់ពីប្តីឈ្មោះ សយ សុភា អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

២. ដើមបណ្តឹងឈ្មោះ «ក» សុំសិទ្ធិអំណាចមេបាលើកូនចំនួន០៣នាក់ កូនទី១.ឈ្មោះ សយ គីមស៊ាង ភេទស្រី កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កូនទី២.ឈ្មោះ សយ គីមហ៊ួច ភេទស្រី កើតនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៧ កូនទី៣.ឈ្មោះ សយ កាលីន ភេទស្រី កើតថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩។

៣. ដើមបណ្តឹងប្រគល់រថយន្តម៉ាកលុចស៊ុស សេរី៤៧០ ឲ្យទៅចុងចម្លើយ ជាកម្មសិទ្ធិ។

៤. ដើមបណ្តឹងប្រគល់ដីទំហំ២០អារ ស្មើនឹង ៣.២០០០ (បីហិចកាពីពាន់ម៉ែត្រ) ដែលមានទីតាំង ស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីលេខ០៨៦/០៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦។ និងដីទំហំ២៥អារ ស្មើនឹង ៤.៦៤០០ (បួនហិចតាប្រាំមួយពាន់បួនរយម៉ែត្រ)មានទីតាំងស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីលេខ០៨៥/០៦ ភព្រ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ។

៥. ដើមបណ្ដឹងប្រគល់ដីទំហំ២៨រ៉ៃ ស្មើនឹង ៣.៨៤០០ (បីហិចតាប្រាំបីពាន់បួនរយម៉ែត្រ) ដែលមានទីតាំង ស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីចុះថ្ងៃទី២ ខែមករា ឆ្នាំ២០០៦ ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ។

៦. សុំប្រគល់ដីទំហំ១៣រ៉ៃ ស្មើនឹង ២.៨០០ (ពីរហិចតាប្រាំបីរយម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង មានលិខិតបញ្ជាក់លក់ដីចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦។ ដីដែលនៅក្នុងភូមិនឃុំផ្ចួចបានរៀបរាប់ខាងលើសរុបចំនួន១៣.៧៦០០(ដប់បីហិចតាប្រាំពីរពាន់ប្រាំមួយរយម៉ែត្រ) ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ។

៧. ដើមចោទសុំសិទ្ធិគ្រប់គ្រងលើដី និងផ្ទះដែលកំពុងសាងសង់មានទីលំនៅស្ថិតនៅភូមិទួលរការ(៣) សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានទំហំ២៨៧,៧០ ម៉ែត្រក្រឡា ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ៣៨៥៧ បជ.មជ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ជាម្ចាស់កម្មសិទ្ធិ។

៨. បំណុលធនាគារចំនួន៣០០០០ (បីម៉ឺនដុល្លារអាមេរិក) ដើមចោទជាអ្នកទទួលសងតែម្នាក់ឯង។

៩. ដីចំការទំហំ ១៣៨៨៨,១២៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចារថ្មី ឃុំអណ្ដូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានកិច្ចសន្យាលក់អចលនវត្ថុលេខ៣៣៥/០៨ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ ដីទំហំបណ្ដោយ៩១ម៉ែត្រ ទទឹង២៦ម៉ែត្រ មានទីលំនៅស្ថិតនៅភូមិស្វាយរៀង ឃុំស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលមានកិច្ចសន្យាទិញ លក់អចលនវត្ថុលេខ ៥៩១/០៨ ឃ.ស្វរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ និងដីស្រែទំហំ១៨៥៥.៣៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលមានលិខិតផ្ទេរកម្មសិទ្ធិកាន់កាប់ដីធ្លីលេខ២៦៧៨/១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។ ដីដែលបានជម្រាបជូន នៅខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង នាងខ្ញុំសូមប្រគល់ទុកឲ្យកូនទាំងបីនាក់។

ការទាមទារចំណុច ១ ប្ដឹងសុំលះបង់រស់នៅផ្ដាច់ទីតិសង្វាសពីប្ដីឈ្មោះ [illegible] អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ នោះចុងចម្លើយបានឯកភាពលែងលះ។

ការទាមទារចំណុច ២ សុំសិទ្ធិអំណាចមេបាលើកូនចំនួន០៣នាក់ កូនទី១.ឈ្មោះ [illegible] ភេទស្រី កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កូនទី២.ឈ្មោះ [illegible] ភេទស្រី កើតនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៧ កូនទី៣.ឈ្មោះ [illegible] ភេទស្រី កើតថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩ និងសុំឲ្យចុងចម្លើយជួយចិញ្ចឹមអាហារកិច្ចកូន ក្នុងមួយខែ៨០០ (ប្រាំបីរយដុល្លារអាមេរិក) រហូតដល់កូនពេញវ័យជានីតិភាព ប៉ុន្តែចុងចម្លើយមិនឯកភាព ដោយចុងចម្លើយសុំសិទ្ធិគ្រប់គ្រងកូនទីមួយ និងទីបី និងសុំឲ្យដើមចោទជួយចិញ្ចឹមអាហារកិច្ចកូនក្នុងមួយខែ១០០០ (មួយពាន់ដុល្លារអាមេរិក) វិញនោះ ខ្ញុំជាដើមចោទមិនឯកភាពតាមសំណូមពររបស់ចុងចម្លើយនោះទេ ដោយហេតុថា ចំនុចនេះខ្ញុំឯកភាពឲ្យកូនទីមួយទៅចុងចម្លើយគ្រប់គ្រង ដោយសារកូនទីមួយមានអាយុច្រើន និងបានរៀនសូត្រមានការយល់ដឹងបានខ្ពង់ខ្ពស់ ហើយខ្ញុំសុំសិទ្ធិគ្រប់គ្រងកូនទីពីរ និងកូនទីបី ដោយសារកូនទាំងពីរនៅតូច និងរៀនសូត្របានតិចតួច ហើយកូនទាំងពីរនាក់នេះកំពុងជាប់សិក្សាដែលមានសាលារៀននៅជិតផ្ទះរបស់

នាងខ្ញុំផ្ទាល់តែម្ដង ដូច្នេះខ្ញុំនៅតែសុំចុងចម្លើយជួយ ចិញ្ចឹមអាហារកិច្ច កូនទាំងពីរក្នុងមួយខែ៨០០ (ប្រាំបីរយដុល្លារអាមេរិក) រហូតដល់កូនពេញវ័យជានីតិភាព។

ការទាមទារចំណុច ៣ ដើមចោទប្រគល់រថយន្តម៉ាកលុចស៊ុស សេរី៤៧០ ឲ្យទៅចុងចម្លើយជាកម្មសិទ្ធិ ហើយចុងចម្លើយក៏បានឯកភាពរួចហើយ ។

ការទាមទារចំណុច៤ ដើមចោទប្រគល់ដីទំហំ២០អ៊ែរ ស្មើនឹង ៣.២០០០ (បីហិចតាពីពាន់ម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីលេខ០៨៦/០៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦។ និងដីទំហំ២៩អ៊ែរ ស្មើនឹង ៤.៦៤០០ (បួនហិចតាប្រាំមួយពាន់បួនរយម៉ែត្រ) មានទីតាំងស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីលេខ០៨៥/០៦ ភព្រ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ហើយចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុច៥ដើមចោទប្រគល់ដីទំហំ២៤អ៊ែរ ស្មើនឹង ៣.៨៤០០ (បីហិចតាប្រាំបីពាន់បួនរយម៉ែត្រ) ដែលមានទីតាំង ស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីចុះថ្ងៃទី២ ខែមករា ឆ្នាំ២០០៦ ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុច៦ដើមចោទប្រគល់ដីទំហំ១៣អ៊ែរ ស្មើនឹង ២.៨០០ (ពីរហិចតាប្រាំបីរយម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង មានលិខិតបញ្ជាក់លក់ដីចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦។ ដីដែលនៅក្នុងភូមិនឃុំដូចបានរៀបរាប់ខាងលើសរុបចំនួន១៣.៧៦០០ (ដប់បីហិចតាប្រាំពីរពាន់ប្រាំមួយរយម៉ែត្រ) ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុច៧ដើមចោទសុំសិទ្ធិគ្រប់គ្រងលើដី និងផ្ទះដែលកំពុងសាងសង់មានទីលំនៅស្ថិតនៅភូមិទួលរការ(៣) សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានទំហំ២៨៧,៧០ ម៉ែត្រក្រឡា ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ៣៨៥៧ បផ-មជ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ជាម្ចាស់កម្មសិទ្ធិចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុច៨បំណុលធនាគារចំនួន៣០០០០ (បីម៉ឺនដុល្លារអាមេរិក) ដើមចោទជាអ្នកទទួលសងតែម្នាក់ឯងចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុច៩ដីចំការទំហំ ១៣៨៨៨,១២៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចារថ្មី ឃុំអណ្ដូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានកិច្ចសន្យាលក់អចលនវត្ថុលេខ៣៣៥/០៨ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ ដីទំហំបណ្ដោយ៩១ម៉ែត្រ ទទឹង២៦ម៉ែត្រ មានទីលំនៅស្ថិតនៅភូមិស្វាយរៀងឃុំស្វាយរៀងក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលមានកិច្ចសន្យាទិញលក់អចលនវត្ថុលេខ៤៨១/០៨ ឃ.ស្វរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ និងដីស្រែទំហំ១៨៥៤,៣៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលមានលិខិតផ្ទេរកម្មសិទ្ធិកាន់កាប់ដីធ្លីលេខ៦៧៨/១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។ ដីដែលបានជម្រាបជូន នៅខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង នាងខ្ញុំសូមប្រគល់ទុកឲ្យកូនទាំងបីនាក់ ប៉ុន្តែនៅក្នុងនិតិវិធីត្រៀមទាញហេតុផល

ចុងចម្លើយមិនឯកភាពដោយសុំបែងចែកជាពីចំណែកស្មើរគ្នានោះ   នៅពេលនេះខ្ញុំមិនចង់អោយរឿងនេះអូសបន្លាយពេលវេលាវែងឆ្ងាយខ្ញុំក៏សុខចិត្តព្រមចែកជាពីរចំណែកស្មើរគ្នា ដោយខ្ញុំសុំចំណែកដីចំការទំហំ ១៣៨៨៨,១២៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយហេតុថា ដីនេះមានទីតាំងនៅជិតរាជធានីភ្នំពេញ ដីមានតែមួយប្លង់ ងាយស្រួលខ្ញុំគ្រប់គ្រងម្យ៉ាងទៀតខ្ញុំជាមនុស្សស្រីនិងគ្រប់គ្រងកូនស្រីផង រីឯដីនៅខេត្តស្វាយរៀងមានរហូតដល់ទៅបីប្លង់និងមានទីតាំងនៅឆ្ងាយពីរាជធានីភ្នំពេញ   ខ្ញុំទុកអោយចុងចម្លើយគ្រប់គ្រងប៉ុន្តែចំណុចនេះប្រសិនបើតុលាការមិនសម្រេចអោយដីចំការទំហំ ១៣៨៨៨,១២៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងមកនាងខ្ញុំទេនោះ   ហើយតុលាការសម្រេចអោយដីទាំង៣កន្លែងនៅខេត្តស្វាយរៀងមកអោយខ្ញុំគ្រប់គ្រងវិញនោះក៏ខ្ញុំព្រមយកទៀត ។

**សន្និដ្ឋាន ៖**

ផ្អែកតាមអង្គហេតុនិង អង្គច្បាប់ខ្ញុំមានសំណូមពរ មេត្តាសម្រេចជាសាលក្រមៈ

សម្រេចតាមថ្លែងការណ៍របស់ខ្ញុំខាងលើ

**១.ខាងឯកសារ ៖**

មានដូចដែលនាងខ្ញុំបានដាក់ជូនភ្ជាប់ក្នុងពាក្យប្តឹងស្រាប់  ។

**២.ខាងសាក្សី ៖**

គ្មាន

រាជធានីភ្នំពេញ,ថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០ ១៣

ស្នាមមេដៃ



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខ 829

ចុះថ្ងៃទី 28 ខែ 4 ឆ្នាំ២០១៥

# កំណត់ហេតុស្តីពីការទាញហេតុផលផ្ទាល់មាត់

(មាត្រា ១១៨ និង មាត្រា ១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

សញ្ញាណរឿងក្ដី ÷

រឿង [illegible]

យើង **ទេព មិត** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

លោក ........................ ជាតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

លោក [illegible] ជាក្រឡាបញ្ជី ។

-ដើមចោទឈ្មោះ [illegible] ភេទ........ អាយុ........ ឆ្នាំ

មុខរបរ [illegible] សញ្ជាតិ.................. សាសនា..................

អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ.......... ផ្លូវ.................. ក្រុម.................. ភូមិ..................

ឃុំ/សង្កាត់.................. ស្រុក/ខណ្ឌ.................. ខេត្ត/រាជធានី..................

ប្រពន្ធ/ប្ដីឈ្មោះ.................. "រ/ស" មានកូន...... នាក់ ឪពុកឈ្មោះ.................. "រ/ស"

ម្ដាយឈ្មោះ.................. "រ/ស" ។

-ចុងចម្លើយឈ្មោះ [illegible] ភេទ........ អាយុ........ ឆ្នាំ

មុខរបរ.................. សញ្ជាតិ.................. សាសនា..................

អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ.......... ផ្លូវ.................. ក្រុម.................. ភូមិ..................

ឃុំ/សង្កាត់.................. ស្រុក/ខណ្ឌ.................. ខេត្ត/រាជធានី..................

ប្រពន្ធ/ប្ដីឈ្មោះ.................. "រ/ស" មានកូន...... នាក់ ឪពុកឈ្មោះ.................. "រ/ស"

ម្ដាយឈ្មោះ.................. "រ/ស" ។

ចុងមេធាវីដើមចោទឈ្មោះ÷..................

មេធាវីចុងចម្លើយឈ្មោះ÷..................

អ្នកជំនួយការឈ្មោះ÷..................

អ្នកបកប្រែភាសាឈ្មោះ÷..................

វេលាម៉ោង.................. ថ្ងៃទី.................. ខែ..................

ឆ្នាំ.................. នៅសាលាដំបូងរាជធានីភ្នំពេញ ។

ខ្លឹមសារនៃបណ្ដឹងសុំរបស់ដើមចោទ÷..................

..................

..................

..................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៨២៩ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥

សាលក្រមរដ្ឋប្បវេណីលេខ: ៨២៦ "ធ" ត.៣.រ.ថ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥

## ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលក្រមចំពោះមុខដើមចោទ និងចំពោះមុខចុងចម្លើយ

កាលបរិច្ឆេទ នៃការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥

កាលបរិច្ឆេទ នៃការប្រកាសសាលក្រមលេខ: ៨២៦ "ទ" ភ.ព.រ.វ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ នៅសាលាដំបូងរាជធានីភ្នំពេញ។

កម្មវត្ថុបណ្ដឹង: ប្ដឹងសុំឈប់រស់នៅជាអនីតិសង្វាស

សមាសភាពជំនុំជម្រះ

-លោក វ៉េង ហ៊ត់ ជាចៅក្រមជំនុំជម្រះ

-លោក មាស ស្អាង ជាក្រឡាបញ្ជីសវនាការ

១. **ភាគីដែលបង្ហាញខ្លួនជាអាទិ៍:**

១.១. ដើមចោទឈ្មោះ «ក» ភេទស្រី អាយុ ៣៥ឆ្នាំ សញ្ជាតិខ្មែរ មានអាស័យដ្ឋានផ្ទះលេខ ៦១សេ ផ្លូវលេខ៣៥៥ ក្រុមទី៥ ភូមិដើមអំពិល មណ្ឌល១១ សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

១.២. ចុងចម្លើយឈ្មោះ «ខ» ភេទប្រុស អាយុ ៣៥ឆ្នាំ សញ្ជាតិខ្មែរ មានអាស័យដ្ឋានផ្ទះលេខ ៦១សេ ផ្លូវលេខ៣៥៥ ក្រុមទី៥ ភូមិដើមអំពិល មណ្ឌល១១ សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

- មេធាវីតំណាងដោយអាណត្តិ ឈ្មោះ ស៊ុន ផល្លា មានការិយាល័យផ្ទះលេខ២៦AE0 ផ្លូវលេខ២១៣ សង្កាត់ច្បារវាលវង្ស ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

២. **សាលក្រមដែលទាមទារដោយដើមចោទ:**

– ប្ដឹងសុំឈប់រស់នៅជាអនីតិសង្វាសជាមួយចុងចម្លើយ

- ដើមចោទសុំប្រគល់ដីទំហំ ១៣៤១ម៉ែត្រការ៉េ ស្ថិតនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ២០០៦០៥០២-០០៤៧ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥
- ដើមចោទសុំប្រគល់ដីទំហំ ២២អ៊ែ នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឱ្យទៅចុងចម្លើយ
- សុំទទួលរ៉ាប់រងនូវបំណុលធនាគារចំនួន ៣០.០០០$ (បីម៉ឺនដុល្លារអាមេរិក) តែម្នាក់ឯង។
- ប្រាក់ប្រដាប់ក្ដីភាគីដើមចោទជាអ្នកទទួលខុសត្រូវ។

៣. __ការពន្យល់រឿងក្ដីត្រួសៗ__

៣.១. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

ដើមចោទ និងចុងចម្លើយបានរៀបការនឹងគ្នាតាមបែបប្រពៃណីខ្មែរល្អ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ ហើយការរួមរស់នៅជាមួយគ្នាប្រសូត្របានកូនចំនួន០៣នាក់ កូនទី១ឈ្មោះ «គី» ភេទស្រី កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ និងកូនទី២ឈ្មោះ «សរ» ភេទស្រី កើតនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៥ និងកូនទី៣ឈ្មោះ «[illegible]» ភេទស្រី កើតនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩។ ការរស់នៅជាមួយគ្នាមិនចុះសម្រុងនឹងគ្នា ដែលជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាក្នុងការរួមរស់នៅជាមួយគ្នាក្នុងនាមជាប្ដីប្រពន្ធតទៅទៀត នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ ដើមចោទក៏បានដាក់ពាក្យបណ្ដឹងសុំឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយតែម្ដង។

៣.២. ភស្តុតាងបញ្ជាក់ការទាមទារដែលមាន:

- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី លេខ៦៧៨/០១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ របស់ចៅសង្កាត់ស្វាយរៀង
- កិច្ចសន្យាទិញ-លក់ អចលនវត្ថុ លេខ៣៤/០៨ ភ.ច.រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨
- លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៨
- កិច្ចសន្យាលក់អចលនវត្ថុ លេខ៣៣៥/០៨ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៨ របស់មេឃុំអណ្ដូងស្វាយ
- កិច្ចសន្យាលក់ដីផ្ដាច់ លេខ៣៤/០៦ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៦ របស់មេឃុំអណ្ដូងស្វាយ
- លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ៣៤៥៧ បជ-មជ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ របស់អភិបាលខណ្ឌមានជ័យ
- លិខិតបញ្ជាក់លក់ដី លេខ០៨៦/០៦ ភព្រ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៤ របស់មេឃុំស្រឡៅ
- ពាក្យសុំផ្ទេរសិទ្ធិដី ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៦

បញ្ជាក់លក់ដី លេខ០៨៦/០៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ និងដីទំហំ២៩អ៊ែរ ស្មើនឹង ៤.៦៥០០ (បួនហិចតាប្រាំមួយពាន់បួនរយម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដី លេខ០៨៥/០៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ហើយចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុចទី៥ ដើមចោទប្រគល់ដីទំហំ២៤អ៊ែរ ស្មើនឹង ៣.៨៤០០ (បីហិចតាប្រាំបីពាន់បួនរយម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៦ ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុចទី៦ ដើមចោទប្រគល់ដីទំហំ១៣អ៊ែរ ស្មើនឹង ២.៨០០ (ពីពាន់ហិចតាប្រាំបីរយម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដី ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦។ ដីដែលមាននៅក្នុងភូមិឃុំដូចបានរៀបរាប់ខាងលើសរុបចំនួន១៣.៧៦០០ (ដប់បីហិចតាប្រាំពីរពាន់ប្រាំមួយរយម៉ែត្រ) ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ហើយចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុចទី៧ ដើមចោទសុំសិទ្ធិគ្រប់គ្រងលើដី-ផ្ទះកំពុងសាងសង់ដែលមានទីលំនៅស្ថិតនៅភូមិទួលរការ៣ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានទំហំ២៨៧,៧០ម៉ែត្រក្រឡា (ពីរម៉ឺនប្រាំបីពាន់ប្រាំពីររយចិតសិប) ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី លេខ៣៤៥៧បជ.មជ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ ជាម្ចាស់កម្មសិទ្ធិ ចុងចម្លើយក៏បានឯកភាពរួចហើយ។

ការទាមទារចំណុចទី៨ ដើមចោទបានថ្លែងក្នុងនីតិវិធីទាញហេតុផល សុំសិទ្ធិគ្រប់គ្រង ដីចំការទំហំ១៣៨៨៨,១២៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀង ខេត្តកំពង់ឆ្នាំង ដែលមានកិច្ចសន្យាលក់អចលនវត្ថុលេខ៣៣៥/០៨ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៨ ចំណែកឯចុងចម្លើយក៏បានឯកភាពដែរ។

ការទាមទារចំណុចទី៩ ដើមចោទសុំប្រគល់ដីស្រែទំហំ១៨៥៤.៣៧ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី លេខ៦៧៨/១៥ ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៥ ឲ្យទៅចុងចម្លើយ ចំណែកឯចុងចម្លើយក៏បានឯកភាព។

ការទាមទារចំណុចទី១០ ដើមចោទសុំសិទ្ធិគ្រប់គ្រងដី ទំហំ១១៨៩ម$^2$ ស្ថិតនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ដែលមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុ លេខ២០០៦០៥០២-០០៤៦ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។

- ដើមចោទសុំសិទ្ធិគ្រប់គ្រងកូនទាំងបី៖ កូនទី១ ឈ្មោះ សយ គីមស៊ាង ភេទស្រី កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ , កូនទី២ ឈ្មោះ សយ គីមហ្គិច ភេទស្រី កើតនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៥ និងកូនទី៣ ឈ្មោះ សយ កាំលីន ភេទស្រី កើតនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩ ចំណែកឯចុងចម្លើយក៏បានឯកភាពដែរ។
- ដើមចោទប្រគល់រថយន្តម៉ាកលុចស៊ីស សេរី៤៧០ ឲ្យទៅចុងចម្លើយ ចំណែកឯចុងចម្លើយ ក៏បានឯកភាពទទួលយកដែរ។
- ដើមចោទប្រគល់ដីទំហំ២០អ៊ែរ ស្មើនឹង ៣.២០០០ (បីហិចតាពីរពាន់ម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដី លេខ០៨៦/០៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ និងដីទំហំ២៩អ៊ែរ ស្មើនឹង ៤.៦៤០០ (បួនហិចតាប្រាំមួយពាន់បួនរយម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដី លេខ០៨៥/០៦ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ហើយចុងចម្លើយក៏បានឯកភាពរួចហើយ។
- ដើមចោទប្រគល់ដីទំហំ២៤អ៊ែរ ស្មើនឹង ៣.៨៤០០ (បីហិចតាប្រាំបីពាន់បួនរយម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដី ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៦ ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ចុងចម្លើយក៏បានឯកភាពរួចហើយ។
- ដើមចោទប្រគល់ដីទំហំ១៣អ៊ែរ ស្មើនឹង ២.៨០០ (ពីពាន់ហិចតាប្រាំបីរយម៉ែត្រ) ដែលមានទីតាំងស្ថិតនៅភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានលិខិតបញ្ជាក់លក់ដីចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦។ ដីដែលមាននៅក្នុងភូមិឃុំដូចបានរៀបរាប់ខាងលើសរុបចំនួន១៣.៧៦០០ (ដប់បីហិចតាប្រាំពីរពាន់ប្រាំមួយរយម៉ែត្រ) ឲ្យទៅចុងចម្លើយធ្វើជាម្ចាស់កម្មសិទ្ធិ ហើយចុងចម្លើយក៏បានឯកភាពរួចហើយ។
- ដើមចោទសុំសិទ្ធិគ្រប់គ្រងលើដី-ផ្ទះកំពុងសាងសង់ដែលមានទីលំនៅស្ថិតនៅភូមិទួលរការ៣ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានទំហំ២៨៧,៧០ម៉ែត្រក្រឡា (ពីរម៉ឺនប្រាំបីពាន់ប្រាំពីររយចិតសិប) ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ៣៤៥៧បជ.មជ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ ជាម្ចាស់កម្មសិទ្ធិ ចុងចម្លើយក៏បានឯកភាពរួចហើយ។
- បំណុលធនាគារចំនួន ៣០.០០០$ (បីម៉ឺនដុល្លារអាមេរិក) ដើមចោទជាអ្នកទទួលសងតែម្នាក់ឯង ចុងចម្លើយក៏បានឯកភាពរួចហើយ។
- ប្រគល់ដីចំការទំហំ១៣៨៤៨,១២៥ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានកិច្ចសន្យាលក់អចលនវត្ថុ លេខ៣៣៥/០៨ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៨ ឲ្យដើមចោទ ចំណែកឯចុងចម្លើយក៏បានឯកភាពដែរ។

## ៦.៤. អំពីកូន៖

ចំពោះកូន ដើមចោទ និងចុងចម្លើយ នៅក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាជាអនីតិសង្វាស ហើយគូភាគីមានកូន ចំនួន៣នាក់គឺ:

- ស. គ>> ភេទស្រី កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២
- ស. ហ>> ភេទស្រី កើតនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៥
- ស. ក>> ភេទស្រី កើតនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៩។

ដើមចោទស្នើសុំសិទ្ធិគ្រប់គ្រងកូនទាំងបី ចំណែកចុងចម្លើយក៏បានឯកភាពទៅនឹងការស្នើសុំនេះដែរ។

តុលាការពិនិត្យទៅលើ ការថែទាំ ចិញ្ចឹមបីបាច់ថែរក្សា ការគ្រប់គ្រងកូនឃើញថា ភាគីដើមចោទ កំពុងថែរក្សាល្អ ផ្តល់ភាពកក់ក្តៅដល់កុមារ តុលាការពិនិត្យផងដែរថា លោកស្រី ប៉ែន សុខន មានមុខរបរត្រឹមត្រូវ អាចមានលទ្ធភាពចិញ្ចឹមបីបាច់ថែរក្សាកូនទាំងបីឲ្យបានល្អ។ ដូច្នេះតុលាការគប្បីសម្រេចប្រគល់កូនឈ្មោះ សយ គីមសាំង ភេទស្រី កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ , សយ គីមហ៊ួច ភេទស្រី កើតនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៧ និងកូនឈ្មោះ សយ កាំលីន ឲ្យទៅលោកស្រី ប៉ែន សុខន ជាម្តាយព្រោះថា កុមារនឹងទទួលផលប្រយោជន៍ច្រើន។

## ៦.៥. អំពីសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

តុលាការយល់ឃើញថា ដើមចោទ សុំទាមទារសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំងបីចំនួន ៣០០$ (បីរយដុល្លារអាមេរិក) ក្នុងមួយខែ ប៉ុន្តែចុងចម្លើយមិនឯកភាពដោយគាត់សុំបង់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ចំនួន១៥០$ (មួយរយហាសិបដុល្លារអាមេរិក) ក្នុងមួយខែ សម្រាប់កូនទាំងបី ដូចនេះតុលាការនឹងធ្វើការសម្រេចដោយគិតទៅលើស្ថានភាពជីវភាពរបស់ចុងចម្លើយ និងផលប្រយោជន៍កូន ស្របតាមមាត្រា១០៤០ កថាខណ្ឌទី៦ នៃក្រមរដ្ឋប្បវេណី[2]។

---

[2] មាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី (សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន) ចែងថា៖

(១) ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។

(២) ឪពុកម្តាយដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និងកំណត់អំពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន។

(៣) ឪពុកដែលមិនរស់នៅជាមួយកូនដែលបានទទួលស្គាល់ អាចពិភាក្សា និងកំណត់ ជាមួយម្តាយអំពីរបៀបចូលជួបប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនបាន។

(៤) បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ និងទី៣ ខាងលើនេះពុំបានសម្រេច ឬបើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនតាមការទាមទាររបស់ឪពុក ឬ ម្តាយ។

(៥) បើទទួលស្គាល់ថា ចាំបាច់ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចផ្លាស់ប្តូររបៀបចូលជួប ប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬម្តាយបាន។

(៦) នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី៤ និងទី៥ ខាងលើនេះ តុលាការត្រូវកំណត់អំពីការចូលជួបប្រាស្រ័យទាក់ទង ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព និងត្រូវកំណត់អំពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយ [...]។

- ដើមចោទសុំសិទ្ធិគ្រប់គ្រងដីទំហំ ១១៨៩ម៉ែត្រការ៉េ ស្ថិតនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ២០០៦០៥០២-០០៤៦ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ចំណែកឯចុងចម្លើយក៏បានឯកភាពដែរ
- ដើមចោទសុំប្រគល់ដីទំហំ ១៣៤១ម៉ែត្រការ៉េ ស្ថិតនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ២០០៦០៥០២-០០៤៧ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ដើមចោទក៏បានឯកភាពទទួលយកដែរ។
- ចុងចម្លើយសុំសិទ្ធិគ្រប់គ្រងដីទំហំ ២២អ៊ែរ ស្ថិតនៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ចំណែកឯដើមចោទក៏បានឯកភាពដែរ ប៉ុន្តែដោយហេតុថា ភស្តុតាងមានតែបង្កាន់ដៃទទួលពាក្យ ដោយមានដាក់ឈ្មោះ ឡុង ស៊ូ មិនមានឈ្មោះ ដើមចោទ និងចុងចម្លើយនោះទេ ដូចនេះតុលាការមិនអាចសម្រេចលើដីនេះបានឡើយ។

តុលាការយល់ឃើញថា ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិរួមរួចហើយ មួយវិញទៀតទ្រព្យសម្បត្តិរួមមានភស្តុតាងគ្រប់គ្រាន់ដែលអាចឱ្យតុលាការសម្រេចបាន លើកលែងតែរថយន្តម៉ាកលុចស៊ីស សេរី ៤៧០ និងដីទំហំ ២២អ៊ែរ ស្ថិតនៅខេត្តបាត់ដំបង ភាគីមិនបានដាក់ភស្តុតាងមកតុលាការនោះទេ ដូចនេះតុលាការគប្បីមិនធ្វើការសម្រេចលើរថយន្ត និងដី ២២អ៊ែរនេះទេ គប្បីធ្វើការសម្រេចទៅតាមការព្រមព្រៀងរបស់ដើមចោទ និងចុងចម្លើយ និងទ្រព្យសម្បត្តិរួមដែលបានដាក់ភស្តុតាងមកតុលាការតែប៉ុណ្ណោះ។

### ៦.៧. បំណុល

នៅក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាជាអនីតិសង្វាស ដើមចោទ និងចុងចម្លើយមានបំណុលរួមដែលបានជំពាក់ធនាគារប្រៃសណីយ៍ចំនួន៣០.០០០$ (បីម៉ឺនដុល្លារអាមេរិក)។ ដើមចោទសុំរ៉ាប់រងលើបំណុលនេះ ចំណែកឯចុងចម្លើយក៏បានឯកភាពដែរ។

តុលាការយល់ឃើញថា ភាគីដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នាលើបំណុលនេះរួចហើយ ដូចនេះគប្បីសម្រេចឱ្យដើមចោទជាអ្នករ៉ាប់រងលើបំណុលនេះតាមការស្នើសុំ។

៦.៨. ចំពោះប្រាក់ប្រដាប់ក្តី ដើមចោទសុំរ៉ាប់រងលើប្រាក់ប្រដាប់ក្តី ចំណែកឯចុងចម្លើយក៏យល់ព្រមឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីនេះដែរ ដូចនេះគប្បីសម្រេចឱ្យដើមចោទរ៉ាប់រងលើប្រាក់ប្រដាប់ក្តី។

## ៧. សេចក្តីសម្រេចបញ្ចប់

៧.១. ទទួលស្គាល់ពាក្យសុំបែកលំនៅសង្វាស របស់ភាគីទាំងពីរ។

៧.២. ឱ្យភាគីដើមចោទឈ្មោះ «ក» ភេទស្រី សញ្ជាតិខ្មែរ និងភាគីចុងចម្លើយឈ្មោះ «ខ» ភេទប្រុស សញ្ជាតិខ្មែរ បែកលំនៅសង្វាសតាមការព្រមព្រៀង របស់ភាគីទាំងពីរ។

៧.១១. ប្រគល់ដីស្រែ ទំហំ១៨៥៤.៣៧ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី លេខ៦៧៨/១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ឱ្យទៅចុងចម្លើយឈ្មោះ «ទ» (តាមការព្រមព្រៀង)។

៧.១២. ប្រគល់សិទ្ធិគ្រប់គ្រងដី ទំហំ១៣៤១ម² ស្ថិតនៅភូមិធ្នល់ ឃុំចេក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ដែលមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុ លេខ២០០៦០៥០២-០០៤៧ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ឱ្យទៅចុងចម្លើយឈ្មោះ «ទ» (តាមការព្រមព្រៀង)។

៧.១៣. បង្គាប់ឱ្យដើមចោទឈ្មោះ «ក» រ៉ាប់រងលើបំណុលរួមដែលបានជំពាក់ធនាគារប្រៃសណីយ៍ ចំនួន៣០.០០០$ (បីម៉ឺនដុល្លារអាមេរិក) (តាមការព្រមព្រៀង)។

៧.១៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទតាមការស្នើសុំ។

ចៅក្រម

ហត្ថលេខា និងត្រា ទេីង ហ៊ត់

---

"ចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥

ក្រឡាបញ្ជី

មាស ស្អាង

បានឃើញ

អធិបតីប្រធាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ...៩១)...យ.ក.រ.អ.កា

**ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តី**

**តុលាការក្រៅពីពន្ធ**

**អនុប្រធាន ទើប ហ៊ាត់ ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ មាត្រា៦២កថាខណ្ឌ៣នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/ ០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ៦៩៧ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ។

- រាំងដើមបណ្តឹងឈ្មោះ «ក» ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរមានទីលំនៅបច្ចុប្បន្នផ្ទះលេខ៦១C ផ្លូវ៣៥៨ក្រុមទី៥ភូមិដើមអំពិលមណ្ឌល១១ សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

និងចុងចម្លើយ លោក «ខ» ភេទ ប្រុស អាយុ ៣៥ ឆ្នាំ ជនជាតិ ខ្មែរ ជនជាតិ ខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៦៩០ ផ្លូវម៉ៅ1214 សង្កាត់ជ័យជំនះខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ដែលមានកម្មវត្ថុបណ្តឹងៈ សុំឈប់រស់នៅជាអនីតិសង្វាស

**សំអាងហេតុ**

-ដើម្បីដំណើរការនីតិវិធីតាមច្បាប់

-រឿនក្តីនេះដំណើរការទៅបានលុះត្រាបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពន្ធ ជាមុនសិន។

**ហេតុដូច្នេះសម្រេច**

១/ បង្គាប់ឲ្យដើមចោទ ឈ្មោះ «ក» ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធចំនួន ១០០០០០ (ដប់ម៉ឺន) រៀល នៅសាលាដំបូងរាជធានីភ្នំពេញ ឲ្យបានមុនថ្ងៃទី ១២ខែឧសភាឆ្នាំ២០១៥ ជាកំណត់ ដើម្បីតុលាការចាត់ការរឿងក្តីនេះតាមច្បាប់ ។

២/ ករណីមិនអនុវត្ត ចំណុចទី ១ ដែលបានចែងខាងលើ និងលើកបណ្តឹងចោលតាមច្បាប់ ។

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៥

ចៅក្រមជំនុំជម្រះ

ទើប ហ៊ាត់

អ្នកទទួល

ថ្ងៃទី..០៤..ខែ...០៥...ឆ្នាំ២០១៥

ហត្ថលេខា ឬ ស្នាមមេដៃ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ...........“ទ” ស.រ.ស្ព

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រម

*យើង មាស ស្នាង ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ*

-បានឃើញមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ **៨២៩** ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ **៨២៦ “ឆ” ភ.ព.ស.វ** ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញពាក្យសុំ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ របស់ឈ្មោះ [illegible] ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៦១សេ ផ្លូវលេខ៣៥៤ ក្រុម៣ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានខ្លឹមសារស្នើសុំបញ្ជាក់សាលក្រមចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណីលេខ **៨២៦** “ឆ” ភ.ព.ស.វ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

## សូមបញ្ជាក់ថា

១-សាលក្រមរដ្ឋប្បវេណីលេខ **៨២៦** “ឆ” **ភ.ព.ស.វ** ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជាស្ថាពរចាប់ពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៥ រួចហើយ ។

២-លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមរដ្ឋប្បវេណីនេះ ចេញឲ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី.... ខែសីហា ឆ្នាំ២០១៥

ក្រឡាបញ្ជី

មាស ស្នាង

រំនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ទទួល ថ្ងៃទី 13 ខែ 08 ឆ្នាំ 2015

ពាក្យសុំរូបមន្តអនុវត្ត

ខ្ញុំឈ្មោះ «ក» ភេទស្រី អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៦១សេ ផ្លូវលេខ៣៩៥ ក្រុម៣ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

សាលាដំបូងរាជធានីភ្នំពេញ
លេខចុះបញ្ជី
00145946
13 08 2015

ជូនទៅក្រុមបន្ទប់ -9-
ពិនិត្យ និងចាត់ការ

សូមគោរពចូលមក
លោកប្រធាន សាលាដំបូងរាជធានីភ្នំពេញ

កម្មវត្ថុ: សំណើសុំរូបមន្តអនុវត្ត នៃសាលក្រមរដ្ឋប្បវេណីលេខ ៨២៦ "ទ" ក.ព.រ.វ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

តាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន លោកប្រធាន មេត្តាជ្រាបថា កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ សាលាដំបូងរាជធានីភ្នំពេញបានជំនុំជម្រះ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៨២៩ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៥ ហើយ បានសម្រេចសេចក្ដីតាមអំណាចសាលក្រម ៨២៦ "ទ" ក.ព.រ.វ ចុះថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ២០១៥ ហើយឥឡូវសាលក្រមនេះ បានចូលជាស្ថាពរហើយ។

អាស្រ័យហេតុនេះសូម លោកប្រធាន មេត្តាផ្ដល់នូវរូបមន្តអនុវត្តនៃ សាលក្រមខាងលើឲ្យនាងខ្ញុំដើម្បីយកទៅប្រើប្រាស់តាមផ្លូវច្បាប់ដោយក្ដីអនុគ្រោះ។

សូម លោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥

ស្នាមមេដៃស្តាំ

«ក»

វិនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ 1184 "ណ" រ.វ.រូ

## រូបមន្តអនុវត្តសាលក្រម

*យើង ទាស ស្អាត ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ*

-បានឃើញមាត្រា៣៥៤ , ៣៥៥ និងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៨២៩ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញលិខិតបញ្ជាក់ការចូលស្ថាពរ នៃសាលក្រមលេខ1189ខ"រ.វ.ស្ថា ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ។

-បានឃើញពាក្យសុំចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ «ក» ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ ។

<u>សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្ត មានដូចខាងក្រោម</u>

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ «ក» ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៦១សេ ផ្លូវលេខ៣៥៥ ក្រុម៣ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

អាចអនុវត្តតាមសាលក្រមរដ្ឋប្បវេណីស្ថាពរលេខ ៨២៦ "ខ"ភ.ព.រ.វ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

កូនបំណុលនៃការអនុវត្តឈ្មោះ «ខ» ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៦១សេ ផ្លូវលេខ៣៥៥ ក្រុម៣ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

*សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំឱ្យសម្រេចតាមសាលក្រមស្ថាពរនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តសាលក្រមនេះបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។*

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥

ក្រឡាបញ្ជី

វិនា